នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល** :
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ២៧ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយសហមេត្រី

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

### សំរេច

**មាត្រា១:** ត្រូវបានបំពាក់មេដាយ **សហមេត្រី** ថ្នាក់ **អស្សរិទ្ធិ** ជូនអ្នកជំនាញការជប៉ុន ០៣រូប ដែលមានស្នាដៃល្អក្នុងការចូលរួមសហការបណ្តុះបណ្តាលធនធានមនុស្ស លើវិស័យកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ នៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម ដូចមាននាមខាងក្រោម :-

| | | |
|---|---|---|
| ១-លោកស្រីបណ្ឌិត | KYOKO SAIO | អ្នកជំនាញការជប៉ុន |
| ២-លោកស្រី | YASUKO KITANO | អ្នកជំនាញការជប៉ុន |
| ៣-លោកបណ្ឌិត | KENJI NISHIMURA | អ្នកជំនាញការជប៉ុន |

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវអនុវត្តអនុក្រឹត្យ នេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២៦ ខែ ០៣ ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និងមាត្រា២
-រាជកិច្ច ✓
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** | **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ២៣.៣៤ អនក្រ-បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

## ស ំ រ េ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន និង តំណាងអង្គការប៊ូដា ចំនួន ០៥ រូប ដែលបានបរិច្ចាគថវិកាជួយកសាងសមិទ្ធផលនានា នៅក្នុងស្រុកកណ្តាលស្ទឹង ស្រុក តាខ្មៅ និង ស្រុកស្អាង ខេត្តកណ្តាល ដូចមានរាយនាមខាងក្រោម ÷

**ក-មេដាយមាសស្ថាបនាជាតិ :**

១-លោក **អ៊ុយ សារិន** ប្រធានការិយាល័យត្រួតពិនិត្យ ទីចាត់ការគយ និង រដ្ឋាករ

២-លោក **និន ជា** អនុប្រធានការិយាល័យត្រួតពិនិត្យ ទីចាត់ការគយ និង រដ្ឋាករ

៣-លោក **ហេខ ចំណាន** អគ្គនាយកអង្គការប៊ូដា

**ខ-មេដាយប្រាក់ស្ថាបនាជាតិ :**

-លោក **ឃឹម សុផល** អគ្គនាយករងអង្គការប៊ូដា

**គ-មេដាយសំរិទ្ធស្ថាបនាជាតិ :**

-លោក **ឌឹម សាឯម** អគ្គនាយករងអង្គការប៊ូដា

**មាត្រា ២ ៖** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល ៖**

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចក្នុងមាត្រា ១ និង មាត្រា ២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ២៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេន និង ជូនសប្បុរសជនចំនួន ០៦ រូប ដែលបានជួយកសាងសមិទ្ធផលនានាក្នុងវិស័យព្រះពុទ្ធសាសនា ស្ថិតនៅក្នុងវត្តសោម ឃុំសោម ស្រុកគីរីវង់ ខេត្តតាកែវ ដូចមានរាយព្រះនាម និង នាមខាងក្រោម ÷

| | | | |
|---|---|---|---|
| ១-ព្រះតេជគុណ | **ហ៊ិន** | **តុំ** | ចៅអធិការវត្ត |
| ២-ឯកឧត្តមឧត្តមសេនីយ៍ទោ | **ហ៊ុយ** | **កែវ** | ថវិកា ១២.០០០ USD |
| ៣-លោកវរសេនីយ៍ឯក | **ភង** | **សំអឿន** | ថវិកា ១២.៨៦២ USD |
| ៤-លោកវរសេនីយ៍ឯក | **នូ** | **សុខារ** | ថវិកា ១០.០៥០ USD |
| ៥-លោកវរសេនីយ៍ឯក | **ឡា** | **ឡៃ** | ថវិកា ១០.០៥០ USD |
| ៦-លោក | **អេន** | **សំអុល** | ថវិកា ១១.៤០០ USD |

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៣

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ២៣៥ អនក.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

**ស ំ រ េ ច**

**មាត្រា១៖** ត្រូវបានបំពាក់ **មេដាយមាសការងារ** ចំនួន ០២ គ្រឿង ជាកិច្ចបច្ឆាមរណៈ ជូនចំពោះសពមន្ត្រីរាជការចំនួន០២រូប នៃខេត្តសៀមរាប ដែលកន្លងមក លោកទាំងពីរបានបូជាកំលាំងកាយចិត្ត និង បញ្ញា ចូលរួមយ៉ាងសកម្មក្នុងការបំរើជាតិ សាសនា ព្រះមហាក្សត្រ ហើយបានទទួលមរណភាពដោយរោគាពាធ ដូចមានរាយនាមខាងក្រោមនេះ :-

១-លោក **គុច អេង** នាយរងក្រុមអធិការកិច្ច សាលាខេត្តសៀមរាប

២-លោក **ស៊ុន ម៉ឿត** អភិបាលរងស្រុកក្រឡាញ់ ខេត្តសៀមរាប

**មាត្រា២៖** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តសៀមរាប ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៤៣៣ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការផ្តល់មេដាយការងារ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនស្នងការ អភិបាលស្រុក និង មេបញ្ជាការ ចំនួន ០៥ រូប ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ចជូនជាតិមាតុភូមិ ដូចមាននាមខាងក្រោម ÷

**ក-មេដាយមាសការងារ :**

១-លោកវរសេនីយ៍ទោ **ហ៊ី ចាន់** ស្នងការរង នគរបាលខេត្តតាកែវ

២-លោក **តឹក សុខលី** អភិបាលស្រុកគីរីវង់

៣-លោកអនុសេនីយ៍ឯក **សៅ វុទ្ធ** មេបញ្ជាការវរសេនាតូចលេខ ២ កងរាជអាវុធហត្ថ ខេត្តតាកែវ

៤-លោកអនុសេនីយ៍ឯក **ឡេង ផន** មេបញ្ជាការវរសេនាតូច ៣០១ ព្រំដែន

**ខ-មេដាយប្រាក់ការងារ :**

-លោក **ឡុង ខាយ** ប្រធានក្រុមប្រឹក្សាឃុំសោម ស្រុកគីរីវង់

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៧៤៨ អនក្រ-បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយសុវត្ថារា

&&&&&

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ / ០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អគ្គនាយកក្រុមហ៊ុន សុខ គង់ អាហារ័ណ នីហារ័ណ

## សំរេច

**មាត្រា ១** : ត្រូវបានបំពាក់ **មេដាយសុវត្ថារា** ថ្នាក់ **ធិបឌិន្ទ** ជូនអគ្គនាយករង ក្រុមហ៊ុនសូគីម៉ិច ចំនួន ០៥ រូប និង នាយកក្រុមហ៊ុនកាត់ដេរ គង់ ហុង ចំនួន ០១ រូប ដែលបានបំពេញភារកិច្ចយ៉ាងសកម្ម ក្នុងការបំរើជាតិមាតុភូមិ ដូចជា : ការចូលរួមកសាងហេដ្ឋារចនាសម្ព័ន្ធ ផ្នែកសេដ្ឋកិច្ច អប់រំ សង្គមកិច្ច ផ្តល់ការងារដល់ប្រជាពលរដ្ឋ និង ចូលរួមជាមួយរាជរដ្ឋាភិបាល ក្នុងការជួយសង្គ្រោះដល់ប្រជាពលរដ្ឋ ជួបការលំបាកខ្វះខាត និង រងគ្រោះផ្សេងៗ ដូចមានរាយនាមខាងក្រោម ÷

| | | | |
|---|---|---|---|
| ១-លោកឧកញ៉ា | **ស៊ិន** | **សុខណា** | អគ្គនាយករង ក្រុមហ៊ុនសូគីម៉ិច |
| ២-លោក | **ឡាច** | **ស៊ីអ៊ុយ** | អគ្គនាយករង ក្រុមហ៊ុនសូគីម៉ិច |
| ៣-លោក | **ហ៊ី** | **ហេង** | អគ្គនាយករង ក្រុមហ៊ុនសូគីម៉ិច |
| ៤-លោក | **សុខ** | **វណ្ណា** | អគ្គនាយករង ក្រុមហ៊ុនសូគីម៉ិច |
| ៥-លោក | **សុខ** | **ហុង** | អគ្គនាយករង ក្រុមហ៊ុនសូគីម៉ិច |
| ៦-លោក | **សុខ** | **សុវណ្ណនិត** | នាយកក្រុមហ៊ុន កាត់ដេរ គង់ ហុង |

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អគ្គនាយកក្រុមហ៊ុន សុខ គង់ អាហារ័ណ នីហារ័ណ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និង មាត្រា២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៦៧ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **តូមីតា យ៉ាស៊ូម៉ាសា ( Tomita Yasumasa )** សប្បុរសជនជប៉ុន ដែលបានឧបត្ថម្ភថវិកាចំនួន ១៣.០០០ **USD** សំរាប់បំពាក់ប្រព័ន្ធអគ្គិសនីដើរដោយថាមពលព្រះអាទិត្យ នៅស្ពានព្រែកពាមទេវ ក្នុងខេត្តក្រចេះ ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មីនា ឆ្នាំ ២០០៣

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ:...

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

## ស ំ រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **ម៉ាត់ ហ៊ីម** និង ភរិយា អាជីវករទូកដរ ព្រែកឆ្លង ក្នុងស្រុកឆ្លូង ខេត្តក្រចេះ ដែលបានឧបត្ថម្ភថវិកាជួយជីកអណ្តូងជូនប្រជាពលរដ្ឋ និង ជួយចម្លងប្រជាពលរដ្ឋដោយមិនយកប្រាក់ រហូតដល់ការកសាងស្ពានព្រែកឆ្លូងបានរួចរាល់ ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ត្រូវអនុវត្ត អនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ ២០០៣

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ:..........

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ

&&&&&

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត /១១៩៨ /៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស /៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស /រកត /១០៩៥ /០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ប្រធានកាកបាទក្រហមកម្ពុជា

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនប្រតិភូកាកបាទក្រហមអន្តរជាតិ ចំនួន ០៤ រូប ដែលបានធ្វើសហប្រតិបត្តិការល្អ ជាមួយកាកបាទក្រហមកម្ពុជា ក្នុងការងារជួយសង្គ្រោះ ផ្នែកមនុស្សធម៌ ដូចមានរាយនាមខាងក្រោម ÷

| | | |
|---|---|---|
| ១-លោក | **Eduardo R.NIERRAS ( TED )** | ទីប្រឹក្សាបច្ចេកទេស កាកបាទក្រហមអូស្ត្រាលី នៃ កម្មវិធី ហ៊ីវ / អេដស៍ |
| ២-លោកស្រី | **Myoung Hee KIM** | ប្រធានប្រតិភូកាកបាទក្រហមកូរ៉េនៃកម្មវិធីស្វែងរកអ្នកស្ម័គ្រចិត្តផ្តល់ឈាម |
| ៣-កញ្ញា | **Hyun - Ji LEE** | ប្រតិភូកាកបាទក្រហមកូរ៉េ នៃកម្មវិធីស្វែងរកអ្នកស្ម័គ្រចិត្តផ្តល់ឈាម |
| ៤-កញ្ញា | **Soon Young CHOI** | ប្រតិភូកាកបាទក្រហមកូរ៉េ នៃកម្មវិធីស្វែងរកអ្នកស្ម័គ្រចិត្តផ្តល់ឈាម |

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានកាកបាទក្រហមកម្ពុជា ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៣

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និង មាត្រា២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១២៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តតាកែវ

## សំរេច

**មាត្រា ១** : ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** ជូនសប្បុរសជនចំនួន ០៧ រូប ដែលបានចូលរួមជួយកសាងសាលារៀន ព្រះវិហារ សាលាធម្មសភា និងលុបដីបំពេញទីវត្តពោធិមាសអំណែត ស្ថិតនៅឃុំបានកាម ស្រុកព្រៃកប្បាស ខេត្តតាកែវ ដូចមានរាយនាមខាងក្រោមនេះ ៖

***ក_មេដាយមាសស្ថាបនាជាតិ*** :

១_លោកយាយ **ហ៊ឹង ម៊ូ** សប្បុរសជនជនខ្មែររស់នៅសហរដ្ឋអាមេរិក បានឧបត្ថម្ភថវិកាជួយកសាងព្រះវិហារវត្តពោធិមាសអំណែត ស្ថិតក្នុងឃុំបានកាម ស្រុកព្រៃកប្បាស ខេត្តតាកែវ អស់ទឹកប្រាក់ចំនួន ១១.១៤០ ដុល្លារអាមេរិក (ដប់មួយពាន់មួយរយសែសិបដុល្លារអាមេរិក) ។

២_លោក **គាង តុង** និង អ្នកស្រី **ស៊ុយ ច្រាយ** សប្បុរសជនជនខ្មែររស់នៅសហរដ្ឋអាមេរិក បានឧបត្ថម្ភថវិកាជួយកសាងព្រះវិហារវត្តពោធិមាសអំណែត ស្ថិតក្នុងឃុំបានកាម ស្រុកព្រៃកប្បាស ខេត្តតាកែវ អស់ទឹកប្រាក់ចំនួន ១០.៨៤២ ដុល្លារអាមេរិក (ដប់ពាន់ប្រាំបីរយសែសិបពីរដុល្លារអាមេរិក) ។

៣_លោក **តាំង សួន** និង អ្នកស្រី **ម៉ូ យ៉ិច** សប្បុរសជនជនខ្មែររស់នៅសហរដ្ឋអាមេរិក បានឧបត្ថម្ភថវិកាជួយកសាងសាលារៀន សាលាធម្មសភា ព្រះវិហារ និង លុបដីបំពេញទីវត្តពោធិមាសអណ្តែត ស្ថិតក្នុងឃុំបានកាម ស្រុកព្រៃកប្បាស ខេត្តតាកែវ អស់ទឹកប្រាក់ចំនួន ១១.០០០ ដុល្លារអាមេរិក (ដប់ មួយពាន់ដុល្លារអាមេរិក) ។

៤_លោក **ស្រ៊ាង ញ៉ូ** សប្បុរសជនជនខ្មែររស់នៅសហរដ្ឋអាមេរិក បានឧបត្ថម្ភថវិកាជួយកសាងសាលាធម្មសភា វត្តសេដ្ឋី ស្ថិតក្នុងឃុំបានកាម ស្រុកព្រៃកប្បាស ខេត្តតាកែវ អស់ទឹកប្រាក់ចំនួន ១២.៥០០ ដុល្លារអាមេរិក (ដប់ពីរពាន់ប្រាំរយដុល្លារអាមេរិក) ។

***ខ_មេដាយប្រាក់ស្ថាបនាជាតិ*** :

១_លោកយាយ **ណុប ឡូច** សប្បុរសជនជនខ្មែររស់នៅប្រទេសអូស្ត្រាលី បានឧបត្ថម្ភជួយថវិកាកសាងព្រះវិហារ និង លុបដីបំពេញទីវត្តពោធិមាសអណ្តែត ស្ថិតក្នុងឃុំបានកាម ស្រុកព្រៃកប្បាស ខេត្តតាកែវ អស់ទឹកប្រាក់ចំនួន ៥.៥០៣ ដុល្លារអាមេរិក (ប្រាំពាន់ប្រាំរយបីដុល្លារអាមេរិក) ។

២_លោក **ស៊ុយ លាងហុង** សប្បុរសជននៅក្រុងភ្នំពេញ បានឧបត្ថម្ភជួយថវិកាកសាង ព្រះវិហារ និង លុបដីបំពេញទីវត្តពោធិមាសអណ្តែត ស្ថិតក្នុងឃុំបានកាម ស្រុកព្រៃកប្បាស ខេត្តតាកែវ អស់ទឹកប្រាក់ចំនួន ៦.៣១០ ដុល្លារអាមេរិក (ប្រាំមួយពាន់បីរយដប់ដុល្លារអាមេរិក) ។

***គ_មេដាយសំរិទ្ធស្ថាបនាជាតិ*** :

_លោកយាយ **អ៊ាហ៊ី សេងអាយ** សប្បុរសជនជនខ្មែររស់នៅប្រទេសស្វីស បានឧបត្ថម្ភជួយថវិកាកសាងព្រះវិហារ វត្តពោធិមាសអណ្តែត ស្ថិតក្នុងឃុំបានកាម ស្រុកព្រៃកប្បាស ខេត្តតាកែវ អស់ទឹកប្រាក់ចំនួន ៣.០៧២ ដុល្លារអាមេរិក (បីពាន់ចិតសិបពីរដុល្លារអាមេរិក) ។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ៕

*រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៣*

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចក្នុងមាត្រា ១ និងមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ_កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣២ អនក្រ

## សេចក្ដីសម្រេច

## ស្ដីពី

## ការបង្កើតគណៈកម្មាធិការគ្រប់គ្រងការចុះបញ្ជីនាវាសញ្ជាតិកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសេចក្ដីត្រូវការចាំបាច់របស់រាជរដ្ឋាភិបាលក្នុងការគ្រប់គ្រងនាវាសញ្ជាតិកម្ពុជា

## សម្រេច

**ប្រការ១** : បង្កើតគណៈកម្មាធិការគ្រប់គ្រងការចុះបញ្ជីនាវាសញ្ជាតិកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម:

| | | | | |
|---|---|---|---|---|
| ១- ឯកឧត្ដម | **សេង** | **លឹមនៅ** | អនុរដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| ២- ឯកឧត្ដម | **ញាណ** | **ឡេង** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣- ឯកឧត្ដម | **ឡេង** | **ធនយុទ្ធា** | អគ្គនាយកដឹកជញ្ជូននៃក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ៤- បណ្ឌិត | **ជា** | **វ៉ាន់ដេត** | ជំនួយការឯកឧត្ដមទេសរដ្ឋមន្ត្រី សុខ អាន | សមាជិក |
| ៥- លោក | **ឃុយ** | **ហៀង** | អនុប្រធាននាយកដ្ឋានគមនាគមន៍ និងប្រៃសណីយ៍ | សមាជិក |

**ប្រការ២** : គណៈកម្មាធិការនេះ មានភារកិច្ចគ្រប់គ្រងការចុះបញ្ជីនាវាសមុទ្រ និងធ្វើឱ្យប្រសើរនូវស្ថានភាពនាវាដាក់ទង់ជាតិកម្ពុជា ដើម្បីស្ដារកិត្តិយសប្រទេសជាតិឡើងវិញ។

**ប្រការ៣** : គណៈកម្មាធិការនេះ ត្រូវអនុវត្តតាមស្មារតីនៃកិច្ចព្រមព្រៀង ដែលបានចុះហត្ថលេខារវាងតំណាងរាជរដ្ឋាភិបាលកម្ពុជា និងក្រុមហ៊ុនចុះបញ្ជីនាវាសមុទ្រអន្តរជាតិកម្ពុជា។ គណៈកម្មាធិការមានភារកិច្ចតាមដាន និងត្រួតពិនិត្យការអនុវត្តកិច្ចព្រមព្រៀង របស់ក្រុមហ៊ុនចុះបញ្ជីនាវាសមុទ្រអន្តរជាតិកម្ពុជា។

**ប្រការ៤** : គណៈកម្មាធិការនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី លើលិខិតផ្លូវការរបស់ខ្លួន។

**ប្រការ៥** : រាល់បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងសេចក្តីសំរេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ឯកឧត្តម អស់លោក ដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសំរេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មីនា ឆ្នាំ ២០០៣*

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**ចំលងជូន:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៦
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:..៤៧..សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតការិយាល័យសន្តិសុខថ្នាក់ខេត្ត-ក្រុង ប្រចាំនៅខេត្តកណ្តាល

## ការិយាល័យសន្តិសុខថ្នាក់កណ្តាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

-បានឃើញសេចក្តីសម្រេចលេខ ៥៥សសរ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០២ ស្តីពីការបង្កើតគណៈបញ្ជាការ ការពារការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី ៣

-ផ្អែកតាមការចាំបាច់របស់ការិយាល័យសន្តិសុខថ្នាក់កណ្តាល

## សម្រេច

**ប្រការ១** : ត្រូវបានបង្កើតការិយាល័យសន្តិសុខថ្នាក់ខេត្ត ប្រចាំនៅខេត្តកណ្តាល ដែលមានសមាសភាពដូចតទៅ :

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **ឆេត ននៀរ** | អភិបាលខេត្ត | **ប្រធាន** |
| ២-ឯកឧត្តម | **ឃឹម បូរ** | អភិបាលរងទី ១ ខេត្ត | **អនុប្រធាន** |
| ៣-លោកឧត្តមសេនីយ៍ត្រី | **ឡឿង សារុន** | មេបញ្ជាការកងឯកភាពអង្គរក្សសម្តេចនាយករដ្ឋមន្ត្រី | **សមាជិក** |
| ៤-លោកឧត្តមសេនីយ៍ត្រី | **ផុន សាវ៉ាត** | មេបញ្ជាការរងយោធភូមិភាគពិសេស | **សមាជិក** |
| ៥-លោកឧត្តមសេនីយ៍ត្រី | **ចាប តន្ត្រី** | មេបញ្ជាការកងពលតូចលេខ ៩១១ | **សមាជិក** |
| ៦-លោកវរៈសេនីយ៍ឯក | **ឯក គ្រិស្ទ** | ស្នងការនគរបាលខេត្ត | **សមាជិក** |
| ៧-លោកវរៈសេនីយ៍ឯក | **ឈឿ ស៊ីដារ៉ា** | មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងខេត្ត | **សមាជិក** |
| ៨-លោកវរៈសេនីយ៍ឯក | **ជួន សុវណ្ណ** | មេបញ្ជាការកងរាជអាវុធហត្ថខេត្ត | **សមាជិក** |
| ៩-លោក | **ចេង ញ៉ាន់** | នាយខុទ្ទកាល័យសាលាខេត្ត | **សមាជិក** |
| ១០-លោក | **រស់ លន់** | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត | **សមាជិក** |
| ១១-លោក | **អ៊ុំ ធន** | ប្រធានមន្ទីរសុខាភិបាលខេត្ត | **សមាជិក** |
| ១២-លោក | **មាស សឿន** | ប្រធានមន្ទីរសាធារណៈការខេត្ត | **សមាជិក** |
| ១៣-លោកវរៈសេនីយ៍ទោ | **ខ៊ែត សីហា** | ស្នងការរងទី ១ នគរបាលខេត្ត | **សមាជិក** |

**ប្រការ២ :** ការិយាល័យសន្តិសុខថ្នាក់ខេត្តមានភារកិច្ច :

-ផ្សព្វផ្សាយ និងចាត់តាំងអនុវត្តផែនការលេខ ០១ផក ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៣ ស្តីពីផែនការការពារសន្តិសុខ សុវត្ថិភាពក្នុងដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី ៣ របស់ការិយាល័យសន្តិសុខថ្នាក់កណ្តាល ។

-រៀបចំបង្កើតការិយាល័យសន្តិសុខថ្នាក់ខ័ណ្ឌស្រុក ឃុំសង្កាត់ តាមសេចក្តីសំរេចលេខ ០១សណរ ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០០៣ របស់ការិយាល័យសន្តិសុខថ្នាក់កណ្តាល ។

-ទទួលគោលការណ៍ ផែនការផ្សេងៗពីការិយាល័យសន្តិសុខថ្នាក់កណ្តាល និងផ្សព្វផ្សាយដល់ការិយាល័យសន្តិសុខថ្នាក់ខ័ណ្ឌស្រុក ឃុំសង្កាត់ ព្រមទាំងណែនាំចាត់តាំងអនុវត្តឱ្យមានប្រសិទ្ធិភាព ។

-រៀបចំចាត់ចែង និងប្រើប្រាស់កម្លាំងគ្រប់ប្រភេទតាមផែនការកំណត់ និងណែនាំឱ្យកម្លាំងទាំងនោះអនុវត្តបានត្រឹមត្រូវ តាមបទបញ្ជា នីតិវិធីរបស់គ.ជ.ប និងច្បាប់បោះឆ្នោត ។

-ចាត់ចែងប្រើប្រាស់មធ្យោបាយ ឧបករណ៍សំភារៈរបស់បណ្តាអង្គភាពដែលមានស្រាប់ដើម្បីបំរើដល់កិច្ចការពារសន្តិសុខ សណ្តាប់ធ្នាប់សម្រាប់ការបោះឆ្នោត ។

-ប្រមូលផ្តុំពត៌មាន និងសភាពការណ៍ផ្សេងៗពីការិយាល័យសន្តិសុខថ្នាក់ក្រោម ឬកសរុបរាយការណ៍ផ្ញើជូនមកការិយាល័យសន្តិសុខថ្នាក់កណ្តាលឱ្យបានទាន់ពេលវេលា ។

-ពិនិត្យដោះស្រាយពាក្យបណ្តឹង ឬឧប្បត្តិហេតុផ្សេងៗពាក់ព័ន្ធដល់សន្តិសុខនៃការបោះឆ្នោតដែលកើតឡើងក្នុងរង្វង់ភូមិសាស្ត្ររបស់ខ្លួន និងធ្វើរបាយការណ៍ជូនមកកាន់ការិយាល័យសន្តិសុខថ្នាក់កណ្តាលរៀងរាល់ ១៥ ថ្ងៃម្តង ។ ករណីចាំបាច់ត្រូវរាយការណ៍ជាបន្ទាន់មកការិយាល័យសន្តិសុខថ្នាក់កណ្តាល ។

-ធ្វើគំរោងថវិកា ឧបករណ៍សំភារៈ មធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទបំរើការងារបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រសំរាប់មណ្ឌលកណ្តាល ដាក់ជូនការិយាល័យសន្តិសុខថ្នាក់កណ្តាលពិនិត្យសំរេច ។

-ធ្វើរបាយការណ៍ចំណូលចំណាយថវិកា និងការប្រើប្រាស់ឧបករណ៍សំភារៈ មធ្យោបាយលើមូលដ្ឋាននៃគំរោងដែលការិយាល័យសន្តិសុខថ្នាក់កណ្តាលបានធ្វើការបែងចែកដល់ការិយាល័យសន្តិសុខគ្រប់ថ្នាក់ និងកងកម្លាំងទាំងអស់ ។

**ប្រការ ៣**: ការិយាល័យសន្តិសុខថ្នាក់ខេត្តមានសិទ្ធិប្រើប្រាស់ត្រារបស់សាលាខេត្តកណ្តាល និងមានសិទ្ធិបង្កើតក្រុមជំនួយការអចិន្ត្រៃយ៍ដើម្បីជាជំនួយក្នុងការតាមដានគ្រប់សភាពការណ៍ និងជួយដឹកនាំបញ្ជាតាមការណែនាំរបស់ប្រធានការិយាល័យសន្តិសុខថ្នាក់កណ្តាល ។

**ប្រការ ៤**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួង-ការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ អគ្គស្នងការ-ដ្ឋាននគរបាលជាតិ ប្រធានលេខាធិការដ្ឋាន ការិយាល័យសន្តិសុខថ្នាក់កណ្តាល មេបញ្ជាការកងរាជអាវុធហត្ថ-លើផ្ទៃប្រទេស គណៈបញ្ជាការឯកភាពខេត្តកណ្តាល និងសមាសភាពដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះឱ្យមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែមីនា ឆ្នាំ ២០០៣

**ឧបនាយករដ្ឋមន្ត្រី**

**និងជាប្រធានការិយាល័យសន្តិសុខថ្នាក់កណ្តាល**

**ស ខេង**

**កន្លែងទទួលៈ**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី ស ខេង

-គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

-លេខាធិការដ្ឋានការិយាល័យសន្តិសុខថ្នាក់កណ្តាល

-ដូចប្រការ ៤

-សាលាខេត្តកណ្តាល

-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ..៦៤..[illegible]

# សេចក្តីសំរេច

## ស្តីពី

## ការបង្កើតការិយាល័យសន្តិសុខថ្នាក់ខេត្ត-ក្រុង ប្រចាំនៅខេត្តកំពង់ចាម

## ការិយាល័យសន្តិសុខថ្នាក់កណ្តាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

-បានឃើញសេចក្តីសំរេចលេខ ៩៥សសរ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០២ ស្តីពីការបង្កើតគណៈបញ្ជាការការពារការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី ៣

-ផ្អែកតាមការចាំបាច់របស់ការិយាល័យសន្តិសុខថ្នាក់កណ្តាល

## សំរេច

**ប្រការ១ :** ត្រូវបានបង្កើតការិយាល័យសន្តិសុខថ្នាក់ខេត្ត ប្រចាំនៅខេត្តកំពង់ចាម ដែលមានសមាសភាពដូចតទៅ :

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **ខៀវ អំ** | អភិបាលខេត្ត | **ប្រធាន** |
| ២-ឯកឧត្តម ឧត្តមសេនីយ៍ទោ | **ឡើន សុវណ្ណថា** | មេបញ្ជាការយោធភូមិភាគ ២ | **អនុប្រធាន** |
| ៣-ឯកឧត្តម | **ថាវ គីមឡុង** | អភិបាលរងទី ១ ខេត្ត | **អនុប្រធាន** |
| ៤-លោកឧត្តមសេនីយ៍ត្រី | **អ៊ិន ស៊ីដារ៉ា** | មេបញ្ជាការកងពលតូចលេខ ៤ | **សមាជិក** |
| ៥-លោកវរៈសេនីយ៍ឯក | **កុច សុខុន** | ស្នងការនគរបាលខេត្ត | **សមាជិក** |
| ៦-លោកវរៈសេនីយ៍ឯក | **នុប សារ៉ុម** | មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងខេត្ត | **សមាជិក** |
| ៧-លោកវរៈសេនីយ៍ឯក | **ទ៉ា សារិទ្ធិ** | មេបញ្ជាការកងរាជអាវុធហត្ថខេត្ត | **សមាជិក** |
| ៨-លោក | **លន់ លឹមថៃ** | នាយខុទ្ទកាល័យសាលាខេត្ត | **សមាជិក** |
| ៩-លោកវរៈសេនីយ៍ទោ | **សៅ ស្រស់** | ស្នងការរងទី ១ នគរបាលខេត្ត | **សមាជិក** |

**ប្រការ២** : ការិយាល័យសន្តិសុខថ្នាក់ខេត្តមានភារកិច្ច :

-ផ្សព្វផ្សាយ និងចាត់តាំងអនុវត្តផែនការលេខ ០១ផក ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៣ ស្តីពីផែនការការពារសន្តិសុខ សុវត្ថិភាពក្នុងដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី ៣ របស់ការិយាល័យសន្តិសុខថ្នាក់កណ្តាល ។

-រៀបចំបង្កើតការិយាល័យសន្តិសុខថ្នាក់ខ័ណ្ឌស្រុក ឃុំសង្កាត់ តាមសេចក្តីសំរេចលេខ ០១សណរ ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០០៣ របស់ការិយាល័យសន្តិសុខថ្នាក់កណ្តាល ។

-ទទួលគោលការណ៍ ផែនការផ្សេងៗពីការិយាល័យសន្តិសុខថ្នាក់កណ្តាល និងផ្សព្វផ្សាយដល់ការិយាល័យសន្តិសុខថ្នាក់ខ័ណ្ឌស្រុក ឃុំសង្កាត់ ព្រមទាំងណែនាំចាត់តាំងអនុវត្តឱ្យមានប្រសិទ្ធិភាព ។

-រៀបចំចាត់ចែង និងប្រើប្រាស់កម្លាំងគ្រប់ប្រភេទតាមផែនការកំណត់ និងណែនាំឱ្យកម្លាំងទាំងនោះអនុវត្តបានត្រឹមត្រូវ តាមបទបញ្ជា នីតិវិធីរបស់គ.ជ.ប និងច្បាប់បោះឆ្នោត ។

-ចាត់ចែងប្រើប្រាស់មធ្យោបាយ ឧបករណ៍សំភារៈរបស់បណ្តាអង្គភាពដែលមានស្រាប់ដើម្បីបំរើដល់កិច្ចការពារសន្តិសុខ សណ្តាប់ធ្នាប់សម្រាប់ការបោះឆ្នោត ។

-ប្រមូលផ្តុំពត៌មាន និងសភាពការណ៍ផ្សេងៗពីការិយាល័យសន្តិសុខថ្នាក់ក្រោម បូកសរុបរាយការណ៍ផ្ញើជូនមកការិយាល័យសន្តិសុខថ្នាក់កណ្តាលឱ្យបានទាន់ពេលវេលា ។

-ពិនិត្យដោះស្រាយពាក្យបណ្តឹង ឬឧប្បត្តិហេតុផ្សេងៗពាក់ព័ន្ធដល់សន្តិសុខនៃការបោះឆ្នោតដែលកើតឡើងក្នុងរង្វង់ភូមិសាស្ត្ររបស់ខ្លួន និងធ្វើរបាយការណ៍ជូនមកកាន់ការិយាល័យសន្តិសុខថ្នាក់កណ្តាលរៀងរាល់ ១៥ ថ្ងៃម្តង ។ ករណីចាំបាច់ត្រូវរាយការណ៍ជាបន្ទាន់មកការិយាល័យសន្តិសុខថ្នាក់កណ្តាល ។

-ធ្វើគំរោងថវិកា ឧបករណ៍សំភារៈ មធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទបំរើការងារបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រសំរាប់មណ្ឌលកំពង់ចាម ដាក់ជូនការិយាល័យសន្តិសុខថ្នាក់កណ្តាលពិនិត្យសំរេច ។

-ធ្វើរបាយការណ៍ចំណូលចំណាយថវិកា និងការប្រើប្រាស់ឧបករណ៍សំភារៈ មធ្យោបាយលើមូលដ្ឋាននៃគំរោងដែលការិយាល័យសន្តិសុខថ្នាក់កណ្តាលបានធ្វើការបែងចែកដល់ការិយាល័យសន្តិសុខគ្រប់ថ្នាក់ និងកងកម្លាំងទាំងអស់ ។

**<u>ប្រការ ៣</u>** : ការិយាល័យសន្តិសុខថ្នាក់ខេត្តមានសិទ្ធិប្រើប្រាស់ត្រារបស់សាលាខេត្តកំពង់ចាម និងមានសិទ្ធិបង្កើតក្រុមជំនួយការអចិន្ត្រៃយ៍ដើម្បីជាជំនួយក្នុងការតាមដានគ្រប់សភាពការណ៍ និងជួយដឹកនាំបញ្ជាតាមការណែនាំរបស់ប្រធានការិយាល័យសន្តិសុខថ្នាក់កណ្តាល ។

**<u>ប្រការ ៤</u>** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួង-ការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ អគ្គស្នងការ-ដ្ឋាននគរបាលជាតិ ប្រធានលេខាធិការដ្ឋាន ការិយាល័យសន្តិសុខថ្នាក់កណ្តាល មេបញ្ជាការកងរាជអាវុធហត្ថ-លើផ្ទៃប្រទេស គណៈបញ្ជាការឯកភាពខេត្តកំពង់ចាម និងសមាសភាពដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះឱ្យមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០០៣

**ឧបនាយករដ្ឋមន្ត្រី**

**និងជាប្រធានការិយាល័យសន្តិសុខថ្នាក់កណ្តាល**

**ស ខេង**

<u>កន្លែងទទួល:</u>

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី ស ខេង

-គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

-លេខាធិការដ្ឋានការិយាល័យសន្តិសុខថ្នាក់កណ្តាល

-ដូចប្រការ ៤

-សាលាខេត្តកំពង់ចាម

-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ០១ សរណន

## សារាចរណែនាំ

## ស្តីពីការប្រើប្រាស់គ្រូជាប់កិច្ចសន្យា

ផ្អែកតាមខ្លឹមសារនៃព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា និងគោលដៅនៃកំណែទំរង់រដ្ឋបាលសាធារណៈ រាជរដ្ឋាភិបាលយល់ព្រមលើសំណើរបស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីការប្រើប្រាស់ជារៀងរាល់ឆ្នាំគ្រូជាប់កិច្ចសន្យាតាមតំរូវការជាក់ស្តែងរបស់មូលដ្ឋាន ។

កន្លងមកដើម្បីពង្រឹងគុណភាព និងប្រសិទ្ធភាពសេវាអប់រំ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ ១០២ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០០២ ស្តីពីការកំណត់ការចំណាយដោយឡែកសំរាប់អនុវត្តកម្មវិធីសកម្មភាពជាអាទិភាពនៅក្រសួងអប់រំ យុវជន និងកីឡា ។ ទន្ទឹមនឹងនេះ ក្រសួងអប់រំ យុវជន និងកីឡា ក៏បាននិងកំពុងអនុវត្តការជាក់ស្តែងមួយចំនួនដើម្បីឆ្លើយតបនឹងតំរូវការសំណូមពរចាំបាច់ចំពោះ មុខដូចជា :

១. ការប្រឡងជ្រើសរើសគ្រូត្រូវបានរៀបចំដោយមានលក្ខណៈទន់ភ្លន់ និងដោយផ្តល់អាទិភាពពិន្ទុចំពោះបេក្ខជនដែលស្ម័គ្រចិត្តទៅបំរើការនៅតាមតំបន់ដាច់ស្រយាល និងជួបការលំបាក

២. ការបែងចែកគ្រូថ្មី ដែលបញ្ចប់ការបណ្តុះបណ្តាលអោយទៅបំរើការងារតាមសាលារៀនកំពុងខ្វះគ្រូ

៣. ការអនុវត្តន៍ការពង្រាយគ្រូតាមស្ថានភាពជាក់ស្តែងរបស់មូលដ្ឋានសាលារៀន

៤. ការបំផុសអោយបង្រៀនពីរពេល ពីរថ្នាក់ និងថ្នាក់គួប

៥. ការឧបត្ថម្ភជីវភាពបន្ថែមជូនគ្រូ ដែលបំរើការងារនៅតំបន់ដាច់ស្រយាល និងជួបការលំបាក ។

វិធានការទាំងអស់នេះ គឺជាការអនុវត្តន៍ជាក់ស្តែងតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ពិសេសកំណែទំរង់រដ្ឋបាលសាធារណៈ ក្នុងន័យរក្សាបរិមាណស្ថិររបស់មន្ត្រីរាជការស៊ីវិល ។

ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលអនុញ្ញាតអោយក្រសួងអប់រំ យុវជន និងកីឡា ជ្រើសរើសគ្រូជាប់កិច្ចសន្យាតាមការចាំបាច់ជាក់ស្តែងក្នុងឆ្នាំនីមួយៗសំរាប់សាលារៀនដែលខ្វះគ្រូ ។ គ្រូជាប់កិច្ចសន្យាអាចប្រឡងចូលក្របខ័ណ្ឌរដ្ឋ ដែលបានកំណត់នៅក្នុងលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌគ្រូបង្រៀន ។ ចាប់ពីពេលនេះតទៅសំណើសុំចូលក្របខ័ណ្ឌជាស្វ័យប្រវត្តិ របស់គ្រូជាប់កិច្ចសន្យាមិនត្រូវបានអនុញ្ញាត ឡើយ ។

ទទួលបានសារាចរណែនាំនេះ ក្រសួងអប់រំ យុវជន និងកីឡា និងស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តខ្លឹមសារខាងលើដោយស្មារតីទទួលខុសត្រូវ និងមានប្រសិទ្ធភាពខ្ពស់ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០០៣

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**<u>ចម្លងជូនៈ</u>**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិកាដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិកាដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-គ្រប់ក្រសួងស្ថាប័ន
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ**...០៦...សរណន

# សារាចរណែនាំ

## ស្តីពីការរៀបចំព្រះរាជពិធី ទិវាវប្បធម៌ជាតិ ០៣ មេសា លើកទី៥ នៃព្រះរាជាណាចក្រកម្ពុជា

★★★★★

អនុវត្តតាមស្មារតីអនុក្រឹត្យលេខ២៤ អនក្រ.បក ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ១៩៩៩ ស្តីពីការបង្កើត"ទិវាវប្បធម៌ជាតិ" រាជរដ្ឋាភិបាលបានកំណត់យកថ្ងៃទី ០៣ ខែមេសា រៀងរាល់ឆ្នាំ ធ្វើជា **"ទិវាវប្បធម៌ជាតិ"** នៃព្រះរាជាណាចក្រកម្ពុជា ។

វប្បធម៌ជាតិ ជាមធ្យោបាយគន្លឹះ នាំឱ្យពលរដ្ឋគោរពច្បាប់ ស្រឡាញ់មនុស្សជាតិ រួបរួមឯកភាពជាធ្លុងមួយ ក្នុងគោលដៅរួមរស់សុខសាន្តជាមួយគ្នា ជាសង្គមសុខដុមរមនា និង ស្រឡាញ់រក្សាសម្បត្តិវប្បធម៌ជាកេរដំណែលព្រមទាំងចេះផ្តួចផ្តើមច្នៃប្រឌិតបង្កបង្កើតសម្បត្តិវប្បធម៌ថ្មី ជំរុញសង្គមឱ្យអភិវឌ្ឍជាប្រចាំ ។

ក្នុងស្ថានភាពដែលពិភពលោកកំពុងអនុវត្តនយោបាយសកលភាវូបនីយកម្ម នៅឆ្នាំ២០០៣នេះ រាជរដ្ឋាភិបាលបានផ្តោតការយកចិត្តទុកដាក់ និងខិតខំប្រឹងប្រែងរៀបចំសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានផ្សេងៗក្នុងវិស័យវប្បធម៌ ដើម្បីធានាឱ្យមានតម្លាភាព និងប្រែក្លាយបាតុភូតសកលភាវូបនីយកម្ម ឱ្យទៅជាកំលាំងវិជ្ជមាន សំរាប់ការលើកតម្កើង អភិរក្ស និងអភិវឌ្ឍន៍វប្បធម៌ជាតិ ដែលនឹងនាំឱ្យមានការទទួលស្គាល់និងផ្តល់តម្លៃខ្ពង់ខ្ពស់ ជាអន្តរជាតិ ដល់មរតកវប្បធម៌ជាតិកម្ពុជាបន្ថែមទៀត ដើម្បីអនុវត្តគោលដៅចំបងទាំងបីរបស់រាជរដ្ឋាភិបាល គឺ :

-ការកាត់បន្ថយភាពក្រីក្រ

-ការអភិវឌ្ឍសង្គមប្រកបដោយចីរភាព

-ការកសាងសមធម៌ និង យុត្តិធម៌សង្គម ។

ក្នុងការរៀបចំទិវាវប្បធម៌ជាតិ ០៣ មេសា លើកទី៥ ឆ្នាំ២០០៣ នេះ រាជរដ្ឋាភិបាលបានសំរេចបន្តអនុវត្តនយោបាយអភិរក្ស និងអភិវឌ្ឍវប្បធម៌ ដើម្បីសមធម៌សង្គម និងកំណត់លើកយកប្រធានបទដែលមានខ្លឹមសារ **"លើកតម្លៃវប្បធម៌ជាតិ ក្នុងការអភិវឌ្ឍសង្គម"** ក្នុងគោលបំណង :

-ជំរុញការអភិវឌ្ឍធនធានមនុស្ស ដែលជាចំណុចស្នូលនៃការអភិវឌ្ឍវប្បធម៌ជាតិ ជាពិសេសធ្វើឱ្យបានកាន់តែល្អប្រសើរនូវសមត្ថភាព និងគុណភាពអប់រំវិស័យសិល្បៈ នៅសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ និងតាមគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន

-រៀបចំជាពិសេសតំបន់ប្រាសាទសំបូរព្រៃគុក ប្រាសាទព្រះវិហារ ប្រាសាទបន្ទាយឆ្មារ និងប្រាសាទបន្ទាយទ័ព ឱ្យទៅជារមណីយដ្ឋានទេសចរណ៍វប្បធម៌

-ជំរុញវិស័យសិល្បៈទស្សនីយភាព រៀបចំការសម្តែងសិល្បៈឱ្យបានត្រឹមត្រូវតាមក្បួនខ្នាតជាតិ សំរាប់បំរើទស្សនិកជនជាតិ អន្តរជាតិ

-បង្កើនការផ្សាយវប្បធម៌ខ្មែរតាមគ្រប់រូបភាព ពិសេសតាមវិទ្យុ ទូរទស្សន៍ សារព័ត៌មាន និងអ៊ីនធឺណែត

-បង្កើនការអប់រំខ្មែរគ្រប់រូបឱ្យយល់ពីតម្លៃវប្បធម៌ជាតិ ក្នុងការអភិវឌ្ឍសង្គម ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ បញ្ចេញសកម្មភាពរួមគ្នាជាឯកច្ឆ័ន្ទ និងជាបន្ទាន់ ក្នុងការធ្វើឱ្យមានតម្លៃ និងថែរក្សាវប្បធម៌ជាតិឱ្យបានគង់វង្ស ប្រកបដោយលក្ខណចរិតជាតិចំរើនជឿនលឿនថ្កុំថ្កើងថ្លៃថ្នូរ និងអនាគតភ្លឺស្វាងសំរាប់មនុស្សជំនាន់ក្រោយ ។

ដើម្បីឱ្យការរៀបចំពិធីទិវាវប្បធម៌ជាតិ ០៣ មេសា នេះ ប្រព្រឹត្តទៅបានល្អប្រសើរ រាជរដ្ឋាភិបាលសូមធ្វើការណែនាំដូចតទៅ :

១-គ្រប់ក្រសួងស្ថាប័ន អាជ្ញាធរខេត្តក្រុង គ្រប់វត្តអារាម គ្រឹះស្ថានសាធារណៈ ប្រព័ន្ធឃោសនា ក្រុមហ៊ុនឯកជន អង្គការ សមាគមនានា ត្រូវ :

-សំដែងការអបអរសាទរទិវាវប្បធម៌ជាតិ ព្រមទាំងបំផុស និងធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់មន្ត្រីរាជការ កងកំលាំងប្រដាប់អាវុធគ្រប់ប្រភេទ សិស្ស និស្សិត ព្រះសង្ឃ ប្រជាពលរដ្ឋគ្រប់ស្រទាប់ឱ្យយល់ដឹងអំពីនយោបាយវប្បធម៌ជាតិ អត្តសញ្ញាណជាតិ ស្មារតីការពារថែរក្សាវប្បធម៌ជាតិ សិល្បៈបេតិកភណ្ឌវប្បធម៌ជាតិ និងស្លៀកពាក់តាមទំនៀមទំលាប់ ប្រពៃណីដ៏ល្អរបស់ជាតិយើង

-បំផុសឱ្យគ្រប់ក្រសួង ស្ថាប័ន អាគារសាធារណៈ ទីប្រជុំជន វត្តអារាម បូជនីយដ្ឋាន ព្រះវិហារ សាលារៀន គេហដ្ឋាន លើកទង់ជាតិ ទង់ជ្ញាលា និងបដាអបអរសាទរ

-បំផុសឱ្យធ្វើការតុបតែងលំអ និងបំភ្លឺភ្លើងឱ្យបានភ្លឺព្រោងព្រាតនៅរាជធានីភ្នំពេញ គ្រប់ខេត្តក្រុង ខណ្ឌស្រុក ឃុំសង្កាត់ ទីប្រជុំជន វត្តអារាម ។

២-ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈត្រូវ :

-ចងក្រងអត្ថបទ និងបោះពុម្ពរូបភាព (អាហ្វីស) ដើម្បីធ្វើការផ្សព្វផ្សាយជាសាធារណៈ អំពីនយោបាយ វប្បធម៌ ស្មារតីការពារវប្បធម៌ សិល្បៈ បេតិកភណ្ឌវប្បធម៌ជាតិ ទំនៀមទំលាប់ប្រពៃណីដ៏ល្អប្រពៃរបស់ជាតិ និងស្មារតី គោរពច្បាប់ និងបទប្បញ្ញត្តិនានា ស្តីពីការគ្រប់គ្រង និងការពារវប្បធម៌ជាតិ និងបរិស្ថានជាតិ

-រៀបចំពិព័រណ៍ជាតិស្តីពីសមិទ្ធផលវប្បធម៌ ដោយអនុញ្ញាតឱ្យសមាគមវប្បធម៌ និងអាជីវករវប្បធម៌ចូលរួម

-សហការជាមួយគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ អន្តរជាតិ និងស្ថាប័នពាក់ព័ន្ធរៀបចំទិវាវប្បធម៌ជាតិនៅថ្ងៃទី ០៣ មេសា នៅរាជធានីភ្នំពេញ ឱ្យបានទទួលលទ្ធផលល្អប្រសើរ

-មន្ទីរវប្បធម៌ និង វិចិត្រសិល្បៈខេត្តក្រុង សហការជាមួយអាជ្ញាធរដែនដីផ្សព្វផ្សាយអត្ថបទខាងលើនេះ ឱ្យ

បានជ្រួតជ្រាបដល់មូលដ្ឋាន និងសំដែងសិល្បៈជូនប្រជារាស្ត្រទស្សនាកំសាន្ត តាមទីសាធារណៈ ព្រមទាំងបំផុសចលនាប្រជាពលរដ្ឋ លេងល្បែងប្រជាប្រិយរបស់ជាតិ រាំកំសាន្តនៅតាមកន្លែង ដែលមានប្រាសាទបុរាណ រមណីយដ្ឋាន វត្តអារាម ទីប្រជុំជន តាមទំនៀមទំលាប់របស់តំបន់នីមួយៗ

-ធ្វើការជ្រើសរើសវរៈសិល្បករ សិល្បការិនីមានស្នាដៃឆ្នើមប្រចាំឆ្នាំ និងអញ្ជើញវរៈសិល្បករ សិល្បការិនីចាស់ដែលបានជ្រើសរើសជារៀងរាល់ឆ្នាំ តាំងពីឆ្នាំ ១៩៩៣ មកជួបសំណេះសំណាលដើម្បីលើកទឹកចិត្ត ។

៣-ក្រសួងព័ត៌មាន រៀបចំផ្សព្វផ្សាយខ្លឹមសារ ឯកសារ និងបណ្តាសកម្មភាពវប្បធម៌សំខាន់ៗ ដែលបំរើឱ្យទិវាវប្បធម៌ជាតិ ០៣ មេសា តាមរយៈប្រព័ន្ធឃោសនាជាតិ ពិសេស វិទ្យុ ទូរទស្សន៍ជាតិ វិទ្យុ ទូរទស្សន៍ឯកជន និងសារព័ត៌មាន តាមការពិភាក្សា ជាមួយក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ។

៤-ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវធ្វើការណែនាំដល់ស្ថានតំណាងកម្ពុជានៅបរទេស ជួយបង្កលក្ខណៈនិងបំផុសស្មារតីដល់ប្រជាជន សហគមន៍ខ្មែរនៅបរទេសគ្រប់មជ្ឈដ្ឋានដើម្បីចូលរួមក្នុងទិវាវប្បធម៌ជាតិ ០៣ មេសា ក្នុងន័យថែរក្សាការពារអត្តសញ្ញាណជាតិ ។

៥-ក្រសួងធម្មការ និង សាសនា ត្រូវនិមន្តព្រះសង្ឃ ក្រសួងអប់រំយុវជននិងកីឡា ចាត់តាំងមន្ត្រី សិស្ស និស្សិត ក្រសួងទេសចរណ៍ អញ្ជើញក្រុមហ៊ុនទេសចរណ៍ សហការជាមួយអាជ្ញាធរដែនដី ឱ្យចូលរួមធ្វើពលកម្មថែរក្សាបោសសំអាតប្រាង្គប្រាសាទ និងវត្តអារាម ដែលមានក្នុងមូលដ្ឋានរបស់ខ្លួនឱ្យបានផុលផុសល្អប្រសើរ ឱ្យក្លាយទៅជាទម្លាប់ជាប្រចាំ ជាពិសេស ត្រូវបំផុសឱ្យសរសេរកំណាព្យ គូរគំនូរបំរើឱ្យខ្លឹមសារ "**លើកតម្លៃវប្បធម៌ជាតិ ក្នុងការអភិវឌ្ឍសង្គម**" ។

៦-ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ ត្រូវមានផែនការណែនាំដល់គ្រប់ខេត្តក្រុង និងអង្គភាពក្រោមឱវាទ បង្កើនកិច្ចការពារបេតិកភណ្ឌជាតិជាប្រចាំ និងថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់ បង្កឱ្យការរៀបចំទិវាវប្បធម៌ជាតិ ០៣ មេសា បានសំរេចភារកិច្ច ប្រកបដោយក្តីសប្បាយរីករាយ និងសុវត្ថិភាពបរិបូរណ៍ ។

ទទួលបានសារាចរនេះ គ្រប់ក្រសួង ស្ថាប័ន និងអាជ្ញាធរគ្រប់ខេត្តក្រុង ត្រូវអនុវត្តតាមខ្លឹមសារខាងលើនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមិនា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-គ្រប់ក្រសួង ស្ថាប័នខេត្តក្រុង
-ឯកសារ-កាលប្បវត្តិ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១៧៦ សហវ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០៣

## ប្រកាស
## ស្តីពី
## ការតែងតាំងក្រុមប្រឹក្សាភិបាល
## ប្រចាំ
## ក្រុមប្រឹក្សាជាតិគណនេយ្យ

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា,
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា,
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី,
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤/អនក្រ/បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ,
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០២/០១១ ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណនេយ្យសហគ្រាស, សវនកម្មគណនេយ្យសហគ្រាស និង វិជ្ជាជីវៈគណនេយ្យ,
- បានឃើញអនុក្រឹត្យលេខ ០៨/អនក្រ/បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០៣ ស្តីពីសមាសភាពនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិគណនេយ្យ-ក.ជ.គ
- បានឃើញកំណត់ហេតុចុះថ្ងៃទី ២៤ខែ មីនា ឆ្នាំ២០០៣ របស់ក្រុមប្រឹក្សាជាតិគណនេយ្យ-ក.ជ.គ សម័យប្រជុំលើកទី១ អាណត្តិទី១,
- បានឃើញការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សំរេច

ប្រការ១ : តែងតាំង :-

| | | | | |
|---|---|---|---|---|
| ១.- | ឯកឧត្តម | ទី តាឃី | អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជា ប្រធាន |
| ២.- | លោក | គួយ លីម | PriceWateHouseCoppers | ជា អនុប្រធាន |
| ៣.- | លោក | ឃិនន៍ ត័យឈន់ | ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | ជាសមាជិក |
| ៤.- | លោក | ចាន់ សុធី | ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | ជា សមាជិក |
| ៥.- | លោក | ហេង វ៉ាន់ដា | ក្រសួងអប់រំយុវជន និងកីឡា | ជា សមាជិក |
| ៦.- | លោក | អ៊ូ ចាន់តារា | ធនាគារជាតិ នៃ កម្ពុជា | ជា សមាជិក |
| ៧.- | លោក | គាំង គុងហ៊ាង | ធនាគារជាតិ នៃ កម្ពុជា | ជា សមាជិក |
| ៨.- | លោក | ឈិន កុសល | ក្រសួងយុត្តិធម៌ | ជា សមាជិក |
| ៩.- | លោក | ទែត សូភិន | ក្រសួងពាណិជ្ជកម្ម | ជា សមាជិក |
| ១០.- | លោក | ហាវ៉ាណ ស៊ីវិល័យ | សភាពាណិជ្ជកម្ម | ជា សមាជិក |
| ១១.- | អ្នកស្រី | ជុង រ៉ានី | សភាពាណិជ្ជកម្ម | ជា សមាជិក |
| ១២.- | លោក | មាស សក្តិសម | ក្រុមហ៊ុន ម៉ូរីសុន កាក់ & អាសូស្សេរ | ជា សមាជិក |
| ១៣.- | លោក | ទ៊ៃ ហ៊ុយ | KPMG | ជា សមាជិក |

ជាក្រុមប្រឹក្សាភិបាល ក្នុងអាណត្តិទី១ ប្រចាំក្រុមប្រឹក្សាជាតិគណនេយ្យ-កជគ ។

ប្រការ២ : អាណត្តិទី១ ដែលមានរយៈពេលបី "៣" ឆ្នាំ ត្រូវបានគិតចាប់ពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៣ ដល់ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៦ ។

ប្រការ៣ : អគ្គលេខាធិការ, នាយកខុទ្ទកាល័យ, ប្រធាននាយកដ្ឋានបុគ្គលិក, ប្រធាននាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ, អង្គភាពពាក់ព័ន្ធ ព្រមទាំងសាមីជន ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ , តាមភារៈកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**គាត ឈន់**

*កម្មវិធាន* :-
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួង/ស្ថាប័នពាក់ព័ន្ធ
"ដើម្បីជូនជ្រាប"
-ដូចប្រការ៣
-ឯកសារ/កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ: ១៧២ សហវ.ប្រក

# ប្រកាសណែនាំ

## ស្តីពី ការងារលទ្ធកម្មរបស់ឃុំ សង្កាត់

យោងតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១ និងអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០០២ ស្តីពីប្រពន្ធ័គ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមធ្វើការណែនាំអំពីការងារលទ្ធកម្មរបស់ឃុំ សង្កាត់ ដូចតទៅ ÷

## I . គោលដៅនយោបាយ

១ សំរេចអោយបាននូវភាពទៀងទាត់ និងភាពតែមួយ ក្នុងការឆ្លើយតបទៅនឹងលក្ខខណ្ឌ និងនីតិវិធីក្នុងការអនុវត្តការងារលទ្ធកម្ម សំរាប់អង្គភាព ឬ ស្ថាប័នសាធារណៈទាំងអស់ ។

២ ធានាអោយបាននូវតម្លា ភាពប្រសិទ្ធភាព និងសន្សំសំចៃក្នុងកិច្ចលទ្ធកម្មទំនិញ សាងសង់ និងសេវា។

៣ ផ្តល់នូវឱកាស ឬពេលវេលាមួយដ៏សមស្របចំពោះអ្នកផ្គត់ផ្គង់ និងអ្នកទទួលការ ដើម្បីចូលរួមក្នុងការផ្គត់ផ្គង់ទំនិញ សេវា និងការងារសាងសង់ ក្នុងលក្ខខណ្ឌយុត្តិធម៌ និងស្មើភាព ។

៤ ចៀសវាង ឬកាត់បន្ថយអោយបានជាអតិបរមានូវសកម្មភាព និងការអនុវត្តមិនគប្បី ដែលអាចកើតមានឡើងក្នុងសកម្មភាពលទ្ធកម្ម។

## II. គោលការណ៍ណែនាំ

៥ ការសន្សំសំចៃ និងប្រសិទ្ធិភាព គឺជាគោលការណ៍ជាមូលដ្ឋានសំរាប់ពិចារណាលើការអនុវត្តក្នុងលទ្ធកម្ម ។ សន្សំសំចៃ មានន័យថារាល់ការទិញទំនិញ សាងសង់ និងផ្តល់សេវា ត្រូវចុះកិច្ចសន្យាលើតំលៃទាប និងសមស្របបំផុត ។ រីឯប្រសិទ្ធភាព មានន័យថាការទិញទំនិញ ជួលសេវា ឬការសាងសង់ នឹងប្រព្រឹត្តទៅក្នុងលំនាំមួយ ដែលឆ្លើយតបតាមតំរូវការ លក្ខណៈបច្ចេកទេស គុណភាព និងពេលវេលា ។

## III. និយមន័យរបស់ពាក្យបច្ចេកទេស

៦ ពាក្យបច្ចេកទេសដែលបានប្រើប្រាស់ក្នុងឯកសារនេះ ត្រូវបានកំណត់និយមន័យ ដូចខាងក្រោម:

ក. លទ្ធកម្ម (Procurement) គឺជាការរកបាននូវទំនិញ និងសេវាពាក់ពន្ធ័ ឬជាការជួលអ្នកទទួលការ សំរាប់ការងារសាងសង់ តាមរយៈវិធីសាស្រ្តលទ្ធកម្មសាធារណៈ ។/.

ខ.លទ្ធកម្មសាធារណៈ (Public Procurement) គឺជាលទ្ធកម្មដែលធ្វើឡើងដោយក្រសួង ស្ថាប័ន ខេត្ត ក្រុង ឃុំ សង្កាត់ និងស្ថាប័នដែលរដ្ឋកាន់កាប់ ឬស្វ័យគ្រប់គ្រង ។

គ.ទំនិញ (Goods) គឺជាវត្ថុក្នុងភាពរឹង រាវ ឬជាឧស្ម័នដែលមានតំលៃ ឬផលប្រយោជន៍ សេដ្ឋកិច្ច ដូចជា គ្រឿងចក្រ បរិក្ខារ សំភារៈ គ្រឿងផ្គត់ផ្គង់ វត្ថុសំរាប់ដោះដូរ (Commodities) និង ផលិតផលផ្សេងៗ រួមទាំងអគ្គិសនីផង ។

ឃ.ការងារសាងសង់ (Civil Works) គឺរាល់សកម្មភាពដែលពាក់ពន្ធ័ដល់ការសាងសង់ ការជួសជុល ការធ្វើឡើងជាថ្មី ការតំឡើង ការជីក ការបូម និងការងារប្រហាក់ប្រហែល ដែលបង្កើត អោយមានការប្រើប្រាស់កំលាំងពលកម្ម គ្រឿងម៉ាស៊ីន បរិក្ខារ និងបច្ចេកវិទ្យា ។

ង.សេវា (Services) គឺជាសកម្មភាពដែលពាក់ពន្ធ័ដល់ការប្រើប្រាស់កំលាំងមនុស្ស គ្រឿងបរិក្ខារ ឬបច្ចេកវិទ្យា ដែលនាំមកនូវផលប្រយោជន៍ដល់ស្ថាប័នសាធារណៈ ប៉ុន្តែមិនរាប់បញ្ចូលការងារ សាងសង់ទេ ។

ច.អ្នកទិញ (Buyer) គឺជាស្ថាប័នសាធារណៈ រួមមានទាំងឃុំ សង្កាត់ ដែលបានទំនិញ ពីការទិញ។

ឆ.អ្នកម្ចាស់ការ (Employer) គឺជាស្ថាប័នសាធារណៈ រួមមានទាំងឃុំ សង្កាត់ ( តំណាងដោយ មេឃុំ ចៅសង្កាត់ ) ដែលចុះកិច្ចសន្យាស្តីពីការសាងសង់ ឬសេវាជួលជាមួយអ្នកទទួលការ ។

ជ.អ្នកផ្គត់ផ្គង់ (Supplier) គឺជាឯកត្តជន ឬជាក្រុមហ៊ុន ដែលចុះកិច្ចសន្យាលើការផ្គត់ផ្គង់ទំនិញ ដែលនឹងត្រូវទិញ ។

ឈ.អ្នកទទួលការ (Contractor) គឺជាឯកត្តជន ឬជាក្រុមហ៊ុនដែលចុះកិច្ចសន្យាលើការសាងសង់ ឬសេវាជួល ។

ញ.ទីភ្នាក់ងារ (Agency) រាល់អង្គភាពរបស់រាជរដ្ឋាភិបាល ដែលអនុវត្តតួនាទីសាធារណៈ រួមមាន ក្រសួង ស្ថាប័នរដ្ឋបាលខេត្ត ក្រុង ឃុំ សង្កាត់ និងស្ថាប័នដែលរដ្ឋកាន់កាប់ ឬស្វ័យគ្រប់គ្រង ។

ដ.ការដេញថ្លៃ (Bidding or Tendering) គឺជាសកម្មភាពប្រកួតប្រជែង ដើម្បីធ្វើការផ្គត់ផ្គង់ ទំនិញសេវា ឬការងារសាងសង់ ។

ឋ.សំណើដេញថ្លៃ (Bid or Tender) គឺជាសំណើសុំដើម្បីផ្គត់ផ្គង់ សេវា ឬធ្វើការសាងសង់ ដែលធ្វើឡើងតាមលក្ខខណ្ឌដែលកំណត់ដោយអ្នកទិញ ឬអ្នកម្ចាស់ការ ។

ឌ.លក្ខណៈសម្បត្តិបន្ទាប់ (Post qualification) សកម្មភាពពិនិត្យឡើងវិញនូវលក្ខណៈសម្បត្តិ បច្ចេកទេស និងហិរញ្ញវត្ថុរបស់អ្នកដែលមានតំលៃថោកជាងគេបំផុត ដើម្បីបញ្ជាក់អោយដឹងថា តើគេមានសមត្ថភាពអនុវត្តកិច្ចសន្យាដែរឬទេ?

ឍ.កិច្ចសន្យា (Contract) គឺជាកិច្ចព្រមព្រៀងរវាងអ្នកទិញ និងអ្នកផ្គត់ផ្គង់ ដើម្បីផ្តល់នូវទំនិញ ឬក៏ រវាងអ្នកម្ចាស់ការ និងអ្នកទទួលការ ដើម្បីអនុវត្តការងារសាងសង់ ជួសជុល ឬសេវាកម្ម

ក្នុងលក្ខខណ្ឌដែលស្រុះស្រួលដោយភាគីទាំងពីរ ។

ណ. **អ្នកត្រួតពិនិត្យបច្ចេកទេស** (Technical Supervisor) គឺជាអ្នកដែលត្រូវបានជ្រើសតាំងដោយប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីធ្វើការត្រួតពិនិត្យ បញ្ជាក់ពីបរិមាណ និងគុណភាព ការងារសាងសង់ និងសេវាកម្ម។

ត. **មន្ត្រីគាំទ្របច្ចេកទេស** (Technical Support Official) ជាមន្ត្រីដែលបានជ្រើសរើសមកពីមន្ទីរជំនាញខេត្ត ក្រុង និងត្រូវតែងតាំងដោយអភិបាលខេត្ត ក្រុង មានភារកិច្ចត្រូវត្រួតពិនិត្យតាមដាន ដំណើរការលទ្ធកម្មក្នុងនាមអភិបាលខេត្ត ក្រុង។ ក្នុងករណីមានសំណើពីឃុំ សង្កាត់ មន្ត្រីគាំទ្របច្ចេកទេសត្រូវជួយក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការគ្រប់គ្រង ការងារបច្ចេកទេស ការចាត់ចែងនៃដំណើរការដេញថ្លៃ និងអនុវត្តកិច្ចសន្យា និងអាចបំពេញ ភារកិច្ចការជាអ្នកត្រួតពិនិត្យបច្ចេកទេសផងដែរដោយមិនគិតថ្លៃ។

## IV. គោលការណ៍ទូទៅ

៧ ឃុំ សង្កាត់ ត្រូវអនុវត្តកិច្ចលទ្ធកម្មសំណង់ សំភារៈឬទំនិញ និងសេវា តាមគោលការណ៍ទូទៅនៃអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ១៩៩៥ ស្តីពីការគ្រប់គ្រងលទ្ធកម្មសាធារណៈ និងប្រការទាំងឡាយនៃអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី ០២ ខែមេសា ឆ្នាំ២០០២ ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់ ។

៨ មេឃុំ ចៅសង្កាត់ ត្រូវទទួលខុសត្រូវចំពោះកិច្ចលទ្ធកម្មការងារសំណង់ សំភារៈឬទំនិញ និងសេវា។

៩ កិច្ចលទ្ធកម្មអភិវឌ្ឍន៍មូលដ្ឋានសំរាប់សំណង់ សំភារៈឬទំនិញ និងសេវាត្រូវផ្តល់កិច្ចសន្យាជាលាយលក្ខអក្សរ (គំរូប្រហាក់ប្រហែលអំពីកិច្ចសន្យាលទ្ធកម្មការងារសាងសង់ សំភារៈឬទំនិញ និងសេវាមានភ្ជាប់ ជាមួយប្រកាសនេះ)

១០ មេឃុំ ចៅសង្កាត់ ត្រូវបង្កើតគណៈកម្មការលទ្ធកម្មមួយ ដោយអនុលោមតាមមាត្រា ៤៦ នៃអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០០២ ស្តីពីប្រពន្ធ័គ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់ ។ គណៈកម្មការលទ្ធកម្ម ទទួលបន្ទុកការងារពិនិត្យលើសំណើរបស់អ្នកផ្គត់ផ្គង់ ឬអ្នកទទួលការ (អ្នកម៉ៅការ) និងផ្តល់អនុសាសន៍ទៅមេឃុំ ចៅសង្កាត់លើដំណើរការត្រឹមត្រូវនៃការងារលទ្ធកម្ម ។ គណៈកម្មការលទ្ធកម្ម ត្រូវធានាថា:

- លទ្ធកម្មការងារសាងសង់ សំភារៈឬទំនិញ និងសេវា ត្រូវបានប្រព្រឹត្តទៅប្រកបដោយកម្លាភាព និង សន្សំសំចៃខ្ពស់។
- អ្នកទទួលការ និងអ្នកផ្គត់ផ្គង់ ត្រូវបានផ្តល់ឱកាសស្មើៗគ្នាក្នុងការចូលរួមប្រកួតប្រជែងក្នុងការងារសាងសង់ ផ្គត់ផ្គង់សំភារៈឬទំនិញ និងផ្តល់សេវា ក្រោមលក្ខខណ្ឌតែមួយ ។

- លទ្ធផលនៃការដេញថ្លៃ ត្រូវប្រកាសជាសាធារណៈ ។

១១ គណៈកម្មការលទ្ធកម្ម ត្រូវអនុវត្តវិធីសាស្ត្រដេញថ្លៃដោយប្រកួតប្រជែងជាចំហ សំរាប់ការងារសាងសង់ ផ្គត់ផ្គង់សំភារៈឬទំនិញ និងសេវា ចំពោះការចំណាយ និងតាមលក្ខខណ្ឌដូចខាងក្រោមៈ

- រាល់ការចំណាយសំរាប់អភិវឌ្ឍន៍មូលដ្ឋាន ៈ ដោយមិនគិតពីទំហំទឹកប្រាក់នៃកិច្ចសន្យានីមួយៗទេ ។
- ការចំណាយសំរាប់សកម្មភាពដទៃទៀត ៈ ដែលមានទំហំទឹកប្រាក់លើសពី ២ លានរៀល ក្នុងកិច្ចសន្យានីមួយៗ ។

១២ គណៈកម្មការលទ្ធកម្ម ត្រូវមានសមាសភាពដូចខាងក្រោមៈ

ក. មេឃុំ ចៅសង្កាត់ ឬអ្នកទទួលសិទ្ធិ ប្រធាន

ខ. សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ពីររូប ដែលជ្រើសតាំងដោយ
ក្រុមប្រឹក្សាឃុំ សង្កាត់ សមាជិក

គ. ស្មៀនឃុំ សង្កាត់ លេខាធិការ

ប្រធានគណៈកម្មការលទ្ធកម្មត្រូវអញ្ជើញមន្ត្រីគាំទ្របច្ចេកទេស និងអ្នកសង្កេតការណ៍មួយចំនួនទៀតចូលរួម។ លេខាធិការ មន្ត្រីគាំទ្របច្ចេកទេស និងអ្នកសង្កេតការណ៍មិនមានសិទ្ធិសំរេចទេ។ គណៈកម្មការលទ្ធកម្មត្រូវសំរេចដោយមតិភាគច្រើនហើយស្របតាមនីតិវិធី និងលក្ខណៈបច្ចេកទេសវាយតំលៃរបស់លទ្ធកម្ម។

១៣ គណៈកម្មការលទ្ធកម្ម ត្រូវធ្វើសេចក្តីសំរេចចិត្តដោយសម្លេងភាគច្រើន ។ ក្នុងករណីដែលមានសំលេងស្មើគ្នា សំលេងរបស់ប្រធានគណៈកម្មការ ចាត់ទុកជាសំលេងឧត្តមភាព។

១៤ មេឃុំ ចៅសង្កាត់ ត្រូវកំណត់កាលបរិច្ឆេទ និងទីកន្លែងសំរាប់ការប្រជុំរបស់គណៈកម្មការលទ្ធកម្ម ដោយធ្វើសហប្រតិបត្តិការជាមួយការិយាល័យរដ្ឋបាលមូលដ្ឋានខេត្ត ក្រុង ។

១៥ ដើម្បីអោយមានប្រសិទ្ធភាពខ្ពស់ ឃុំ សង្កាត់ត្រូវរៀបចំការដេញថ្លៃប្រចាំឆ្នាំតែមួយលើក ដើម្បីផ្តល់កិច្ចសន្យាទាំងអស់ សំរាប់ការវិនិយោគអភិវឌ្ឍន៍មូលដ្ឋាន ក្នុងឥណទានថវិកាដែលបានអនុម័ត ។

១៦ ឃុំ សង្កាត់ មិនត្រូវទូទាត់ប្រាក់អោយអ្នកទទួលការ ឬអ្នកផ្គត់ផ្គង់ជាមុនទេ ។ ការទូទាត់ត្រូវធ្វើឡើងតែនៅពេលណាដែលសំណង់ សំភារៈឬទំនិញ ត្រូវបានប្រគល់ ទទួល ឬសេវាកម្មត្រូវបានបំពេញត្រឹមត្រូវ តាមលក្ខណៈបច្ចេកទេស និងលក្ខខណ្ឌដែលមានចែងក្នុងកិច្ចសន្យា ។

## V. វិធីសាស្ត្រលទ្ធកម្ម

១៧ ជាទូទៅកិច្ចលទ្ធកម្មនឹងប្រព្រឹត្តទៅក្នុងលំនាំពីរយ៉ាងគឺៈ

- ការដេញថ្លៃដោយប្រកួតប្រជែងជាចំហ (ជាសាធារណៈ)
- វិធីផ្សេងទៀតដែលមិនមែនជាការដេញថ្លៃដោយប្រកួតប្រជែងជាចំហ

## V.1 វិធីសាស្ត្រដេញថ្លៃដោយប្រកួតប្រជែងជាចំហ

ការដេញថ្លៃដោយប្រកួតប្រជែងជាចំហ ត្រូវបានយកមកប្រើប្រាស់ នៅពេលដែលមានអ្នកផ្គត់ផ្គង់ ឬអ្នកទទួលការច្រើនគ្រប់គ្រាន់ ( យ៉ាងតិច ៣ ) ដែលអាចផ្តល់ទំនិញ សេវា ឬ ការសាងសង់ ជួសជុលដែលចង់បាន ។ ការងារនេះនឹងផ្តល់អត្ថប្រយោជន៍ដល់ឃុំ សង្កាត់ ប្រសិនបើការប្រកួតប្រជែងនឹងនាំទៅដល់ការជ្រើសរើសអ្នកផ្គត់ផ្គង់ ឬអ្នកទទួលការណាមួយដែលផ្តល់នូវសំណើមានលក្ខណៈសន្សំសំចៃ និងមានប្រសិទ្ធភាពបំផុត ។

ការប្រកួតប្រជែងជាចំហ អាចធ្វើឡើងដោយលក្ខណៈក្នុងស្រុក ដែលគេអោយឈ្មោះថា ការដេញថ្លៃប្រកួតប្រជែងក្នុងស្រុក (Domestic Competitive Bidding-DCB)។ ឃុំ សង្កាត់ប្រើប្រាស់វិធីសាស្ត្រដេញថ្លៃប្រកួតប្រជែងក្នុងស្រុក សំរាប់ការងារអភិវឌ្ឍន៍មូលដ្ឋាន និងចំពោះកិច្ចសន្យាសំរាប់សកម្មភាពដទៃទៀត ដែលមានទំហំទឹកប្រាក់ចាប់ពី ២ លានរៀល ឡើង នឹងអាចមានអ្នកចូលរួមដេញថ្លៃក្នុងស្រុកយ៉ាងច្រើន អាចផ្តល់នូវលទ្ធភាពដ៏ទូលំទូលាយមួយក្នុងការជ្រើសរើសយកសំណើដែលល្អបំផុត ។ តំលៃនេះអាចពិនិត្យឡើងវិញពីពេលមួយទៅពេលមួយ ប្រសិនបើចាំបាច់ ។ ក្នុងករណីអនុវត្តវិធីសាស្ត្រដេញថ្លៃប្រកួតប្រជែងក្នុងស្រុក វាជាការចាំបាច់ណាស់ ត្រូវមានភស្តុតាងជាក់លាក់ ដើម្បីបញ្ជាក់ពីសមត្ថភាពក្នុងស្រុកដ៏សមស្រប។

## V.2 វិធីសាស្ត្រផ្សេងទៀតដែលមិនមែនជាការដេញថ្លៃ ដោយប្រកួតប្រជែងជាចំហ

វិធីសាស្ត្រផ្សេងទៀតនៃលទ្ធកម្មដែលមិនមែនជាការដេញថ្លៃដោយប្រកួតប្រជែងជាចំហមាន:
- ការស្ទង់តំលៃក្នុងស្រុក
- ការទិញផ្ទាល់ ឬការចុះកិច្ចសន្យាផ្ទាល់

### ក- ការស្ទង់តំលៃក្នុងស្រុក

ការស្ទង់តំលៃក្នុងស្រុក (Domestic Canvassing-DC) គឺតម្រូវអោយមានតារាងតំលៃចំនួនបី យ៉ាងតិច ពីអ្នកផ្គត់ផ្គង់ក្នុងស្រុក ។ វិធីសាស្ត្រនេះត្រូវបានប្រើប្រាស់ក្នុងកិច្ចសន្យាផ្គត់ផ្គង់ដែលទិញផ្ទាល់ពីហាង នូវវាល់វត្ថុ សំភារៈ ឬ គ្រឿងផ្គត់ផ្គង់ គ្រឿងបន្ទាស់ ឬមួយជាគ្រឿងម៉ាស៊ីនតូចតាច និងបរិក្ខារ ដែលអាចផ្តល់ដោយអ្នកផ្គត់ផ្គង់ក្នុងស្រុក នៅតាមមូលដ្ឋាន ឬមួយក៏ភ្នាក់ងារទទួលសិទ្ធិនៃអ្នកផ្គត់ផ្គង់បរទេស និងប្រើប្រាស់ក្នុងកិច្ចសន្យាសាងសង់ជួសជុលដែលមានទំហំទឹកប្រាក់មិនធំ។ ក៏ប៉ុន្តែវិធីស្ទង់តំលៃក្នុងស្រុក អាចប្រើប្រាស់បានចំពោះកិច្ចសន្យាសំរាប់សកម្មភាពក្រៅពីអភិវឌ្ឍន៍មូលដ្ឋាន ហើយមានទំហំទឹកប្រាក់ចាប់ពី ៤០០.០០០រៀល ដល់ ទាបជាង ២.០០០.០០០រៀល ។

**ខ-ការទិញផ្ទាល់ ឬការចុះកិច្ចសន្យាផ្ទាល់**

ការទិញផ្ទាល់ ឬការចុះកិច្ចសន្យាផ្ទាល់ (Direct purchase-DP) or (Direct contracting-DOC) គឺជាវិធីធ្វើការទាក់ទងចរចាផ្ទាល់ជាមួយអ្នកផ្គត់ផ្គង់ ឬអ្នកទទួលការតែមួយគត់ ហើយត្រូវបានអនុវត្តក្នុងកាលៈទេសៈដូចខាងក្រោមៈ

- តំលៃទំនិញ ឬ សេវា និង ការសាងសង់ ជួសជុលនោះមិនលើសពី ៤០០.០០០រៀល (សំរាប់សកម្មភាពក្រៅពីរភិវឌ្ឍន៍មូលដ្ឋាន)
- វត្ថុដែលត្រូវទិញ តំរូវអោយមានការពង្រីក ឬ ជួសជុលឧបករណ៍ដែលមានស្រាប់
- ឧបករណ៍ដែលនឹងត្រូវបានមកពីអ្នកផ្គត់ផ្គង់តែមួយប៉ុណ្ណោះ
- ទំនិញ សេវា ឬ ការងារសាងសង់ត្រូវការជាបន្ទាន់ដើម្បីទប់ទល់នឹងស្ថានភាពអាសន្ន
- ការបញ្ជាទិញថ្មីដដែលមួយទៀត នូវមុខទំនិញដែលដេញថ្លៃរួចហើយ តាមរយៈការប្រកួតប្រជែងថ្លៃ ហើយវាអាចនឹងគ្មានតំលៃណាទាបជាងនេះទៀតទេ ទោះតាមរយៈការដេញថ្លៃណាផ្សេងទៀតក៏ដោយ
- មិនអាចរកបានអ្នកទទួលការឬអ្នកផ្គត់ផ្គង់ ក្រោយដំណើការនិតិវិធីដេញថ្លៃប្រកួតប្រជែងចប់សព្វគ្រប់។
- ការទិញដែលត្រូវធ្វើឡើងដោយភ្នាក់ងាររដ្ឋាភិបាលណាផ្សេងទៀត ឬការសាងសង់ ដែលត្រូវធ្វើឡើងតាមរយៈស្ថាប័នរដ្ឋ ដោយប្រើប្រាស់មធ្យោបាយផ្ទាល់ ក្នុងករណីចាំបាច់និងបន្ទាន់។

ក្នុងករណីពិសេស ការប្រើវិធីសាស្ត្រលទ្ធកម្មដែលមានតំលៃកិច្ចសន្យាខុសពីប្រការដែលកំណត់ក្នុងផ្នែកនេះ ត្រូវធ្វើការពិនិត្យពីករណីដោយឡែកនីមួយៗ ដោយផ្អែកលើសេចក្តីសំរេចរបស់អភិបាលខេត្ត ក្រុង ។

# VI. នីតិវិធីលទ្ធកម្ម

## VI.1 លទ្ធកម្មការងារសាងសង់

១៨ គ្រប់ការងារសាងសង់ទាំងអស់ ត្រូវចុះកិច្ចសន្យាការងារជាមួយអ្នកម៉ៅការឯករាជ្យ ។ អភិបាលខេត្ត ក្រុង ត្រូវបង្កើតគណៈកម្មការបច្ចេកទេសចុះបញ្ជីអ្នកទទួលការសាងសង់ដែលបានធ្វើបុរេលក្ខណៈសម្បត្តិដើម្បីចូលរួមដេញថ្លៃលើការងារសាងសង់របស់ឃុំ សង្កាត់តាមប្រភេទការងារអោយបានទៀងទាត់ជាប្រចាំ។ អ្នកទទួលការសាងសង់ទាំងអស់ដែលប្រគល់ការងារ ដោយឃុំ សង្កាត់ នឹងត្រូវចុះឈ្មោះនៅក្នុងបញ្ជីអ្នកទទួលការសាងសង់នេះ។

១៩ រាល់កិច្ចសន្យាការងារសាងសង់ទាំងអស់ ត្រូវផ្តល់អោយអ្នកម៉ៅការ តាមវិធីសាស្ត្រដេញថ្លៃប្រកួតប្រជែងក្នុងស្រុក ដែលមាននិតិវិធីតាមទម្រង់ដូចខាងក្រោម : ៤

**ក- ការរៀបចំឯកសារដេញថ្លៃ** ៤

- គណៈកម្មការលទ្ធកម្ម ត្រូវរៀបចំឯកសារដេញថ្លៃដោយមានមន្ត្រីគាំទ្របច្ចេកទេសជាជំនួយការ។
- ឯកសារដេញថ្លៃត្រូវបញ្ជាក់ប្រាប់នូវរាល់ពត៌មានចាំបាច់ទាំងឡាយ ដែលអាចអោយអ្នកដេញថ្លៃប្រមើលមើលដើម្បីធ្វើសេចក្តីសំរេចចិត្តក្នុងការចូលរួមដេញថ្លៃ និងរៀបចំសំណើដេញថ្លៃ។
- ពត៌មានដែលផ្តល់អោយអ្នកចូលរួមដេញថ្លៃត្រូវរួមបញ្ចូលនូវតំលៃប៉ាន់ស្មាន ដែលនឹងត្រូវប្រើជាមូលដ្ឋានសំរាប់ការវាយតំលៃលើសំណើដេញថ្លៃ។

**ខ- ការប្រកាសអញ្ជើញចូលរួមដេញថ្លៃ**

- ការប្រកាសផ្សព្វផ្សាយស្តីពីការអញ្ជើញអោយចូលរួមដេញថ្លៃ ត្រូវធ្វើឡើង ពីរសប្តាហ៍មុនថ្ងៃចាប់ផ្តើមសំណើដេញថ្លៃ ។ ការផ្សព្វផ្សាយពត៌មាន ស្តីពីការអញ្ជើញចូលរួមដេញថ្លៃត្រូវបិទផ្សាយនៅក្តារផ្សាយពត៌មានរបស់ឃុំ សង្កាត់ និងរដ្ឋបាលខេត្ត ក្រុង ។
- ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវចាត់វិធានការបន្ថែមលើការប្រកាសផ្សាយ ដើម្បីធានាអោយមានការចូលរួមដេញថ្លៃជាសាធារណៈ ។

**គ- ការចែកឯកសារដេញថ្លៃ**

- នៅពេលផ្សព្វផ្សាយការអញ្ជើញចូលរួមដេញថ្លៃ ឯកសារដេញថ្លៃ ត្រូវរៀបចំអោយមានជាស្រេច នៅការិយាល័យរដ្ឋបាលឃុំ សង្កាត់ និងលក់ក្នុងតម្លៃប្រហាក់ប្រហែលថ្លៃដើម ជូនចំពោះអ្នកទទួលការដែលចាប់អារម្មណ៍ ។ បន្ថែមលើនេះ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវធានាអោយមានឯកសារដេញថ្លៃគ្រប់គ្រាន់ នៅនឹងការិយាល័យរដ្ឋបាលឃុំ សង្កាត់ ។
- ប្រធានគណៈកម្មការលទ្ធកម្ម ត្រូវរៀបចំអោយមានការប្រជុំមួយ មុនពេលដេញថ្លៃ ស្តីពីការណែនាំលើការងារបច្ចេកទេស និងការត្រួតពិនិត្យលើការដ្ឋានគំរោង ។ ក្នុងករណីមានពត៌មានបន្ថែម ត្រូវផ្តល់ដំណឹងដល់អ្នកចូលរួមដេញថ្លៃ ពត៌មានទាំងនោះត្រូវបញ្ជាក់នៅក្នុងអង្គប្រជុំមុនពេលដេញថ្លៃ ដើម្បីជាផលប្រយោជន៍ដល់អ្នកចូលរួមដេញថ្លៃ ។

**ឃ- ការដាក់ និងទទួលសំណើដេញថ្លៃ**

- សំណើដេញថ្លៃត្រូវដាក់ក្នុងស្រោមសំបុត្របិទជិត ហើយប្រគល់ជូនរដ្ឋបាលឃុំ សង្កាត់ អោយបានមុនថ្ងៃឱសានវាន ។
- សំណើដេញថ្លៃមិនត្រូវបានទទួលយក ឬអនុញ្ញាតកែប្រែថ្ងៃណាមួយក្រោយថ្ងៃឱសានវានឡើយ ។

**ង- ការបើកសំណើដេញថ្លៃ**

- សំណើដេញថ្លៃដែលទទួលបាន ត្រូវបើកជាសាធារណៈតាមកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងកំនត់ នៅចំពោះមុខគណៈកម្មការលទ្ធកម្ម និងអ្នកចូលរួមដេញថ្លៃ ។ h

- ការបើកសំណើដេញថ្លៃ ត្រូវពន្យាពេល ដោយកំនត់កាលបរិច្ឆេទ ពេលវេលា និងទីកន្លែងជាថ្មី ប្រសិនបើមានសមាសភាពគណៈកម្មការលទ្ធកម្មណាម្នាក់ (ប្រធាន ឬសមាជិកគណៈកម្មការលទ្ធកម្ម) អវត្តមាន ។
- នៅពេលកាលបរិច្ឆេទថ្មីនៃការពន្យាពេលឈានមកដល់ ដើម្បីអោយការបើកសំណើដេញថ្លៃមានសុពលភាព ត្រូវមានការចូលរួមពីសមាជិកនៃគណៈកម្មការលទ្ធកម្មយ៉ាងតិចពីររូបដែលក្នុងនោះមានមួយរូបជាប្រធានគណៈកម្មការលទ្ធកម្ម។
- គណៈកម្មការលទ្ធកម្ម ត្រូវធ្វើរបាយការណ៍បើកសំណើដេញថ្លៃ ដែលរួមមានបញ្ជីឈ្មោះអ្នកចូលរួមដេញថ្លៃ តំលៃដាក់ដេញ និងការអង្កេតពាក់ព័ន្ធដទៃទៀត ហើយរបាយការណ៍នេះត្រូវចុះហត្ថលេខាដោយសមាសភាពគណៈកម្មការលទ្ធកម្ម និងអ្នកចូលរួមដេញថ្លៃ ។

**ច- ការវាយតំលៃលើសំណើដេញថ្លៃ និងចុះកិច្ចសន្យា**

- គណៈកម្មការលទ្ធកម្ម ត្រូវវាយតំលៃលើសំណើដេញថ្លៃ ដោយមិនត្រូវអោយខូវខ្វាយពត៌មានមកខាងក្រៅទេ រហូតទាល់តែបានធ្វើការសំរេចរួច។ ការវាយតំលៃលើសំណើដេញថ្លៃត្រូវពន្យាពេល និងកំណត់កាលបរិច្ឆេទ ពេលវេលា និងទីកន្លែងជាថ្មី ប្រសិនបើមានសមាសភាពគណៈកម្មការលទ្ធកម្មណាម្នាក់អវត្តមាន ។
- នៅពេលកាលបរិច្ឆេទថ្មីនៃការពន្យាពេលឈានមកដល់ ដើម្បីអោយការវាយតំលៃលើសំណើដេញថ្លៃមានភាពត្រឹមត្រូវនោះ ត្រូវមានការចូលរួមពីសមាសភាពនៃគណៈកម្មការលទ្ធកម្ម យ៉ាងតិច ពីររូប ដែលក្នុងនោះមានមួយរូប ជាប្រធានគណៈកម្មការលទ្ធកម្ម ។
- ការវាយតំលៃលើសំណើដេញថ្លៃ ត្រូវកំនត់នូវភាពឆ្លើយតបទៅនឹងឯកសារដេញថ្លៃ ហើយបដិសេធនូវសំណើដេញថ្លៃណា ដែលមិនស្របតាមការណែនាំផ្លូវការ ឬមិនឆ្លើយតបទៅនឹងការបញ្ជាក់លក្ខណៈបច្ចេកទេសក្នុងឯកសារដេញថ្លៃ ឬតំលៃមិនត្រឹមត្រូវ។ ចំពោះសំណើដេញថ្លៃណាដែលមានតំលៃទាបជាងតំលៃប៉ាន់ស្មាន ១៥ % គួរតែធ្វើការត្រួតពិនិត្យដោយប្រុងប្រយត្ន័ដើម្បីកំណត់ថាតើតំលៃនោះជាតំលៃសមស្របឬមិនសមស្រប។ រាល់ចំនុចខ្វះខាតនៃសំណើដេញថ្លៃត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ដើម្បីបង្ហាញពីភាពសមហេតុផលលើការបដិសេធនូវសំណើដេញថ្លៃក្នុងពេលវាយតំលៃ ។
- ដំណើរការបន្ទាប់ពីការវាយតំលៃ គឺធ្វើការប្រៀបធៀបតំលៃដេញ ហើយកំនត់ការផ្តល់កិច្ចសន្យាដល់អ្នកដេញថ្លៃណាដែលមានតំលៃទាបជាងគេ ។
- ក្នុងករណីដែលមានតំលៃដេញទាបស្មើគ្នាពីរ ឬច្រើន តំលៃនេះគឺជាមូលដ្ឋានដេញថ្លៃចុះសំរាប់គណៈកម្មការលទ្ធកម្មប្រើវិធីដេញថ្លៃឡើងវិញ តែចំពោះអ្នកចូលរួមដេញថ្លៃណាដែលមានតំលៃដេញទាបស្មើគ្នានោះ ដោយអោយអ្នកដែលត្រូវដេញថ្លៃឡើងវិញទាំងនោះ

"សារសេរតម្លៃដេញថ្លៃថ្មី" ដាក់ក្នុងស្រោមសំបុត្របិទជិត រួចប្រគល់ជូនគណៈកម្មការលទ្ធកម្មព្រមគ្នាក្នុងពេលតែមួយ ហើយគណៈកម្មការលទ្ធកម្មត្រូវបើកស្រោមសំបុត្រទាំងនោះភ្លាមនៅចំពោះមុខដើម្បីកំណត់បានអ្នកដេញថ្លៃឈ្នះដែលមានតំលៃដេញទាបជាងគេ។

- គណៈកម្មការលទ្ធកម្ម ត្រូវដាក់របាយការណ៍បើកឯកសារដេញថ្លៃ និងកំណត់ហេតុវាយតំលៃសំណើដេញថ្លៃដើម្បីប្រគល់កិច្ចសន្យា ជូនមេឃុំ ចៅសង្កាត់ ពិនិត្យនិងសំរេច ។ លិខិតសំរេចជ្រើសរើសអ្នកទទួលការដើម្បីប្រគល់កិច្ចសន្យារបស់មេឃុំ ចៅសង្កាត់ ត្រូវផ្សព្វផ្សាយជាសាធារណៈ និងបិទនៅក្តារពត៌មានរបស់ឃុំ សង្កាត់ ។ មេឃុំ ចៅសង្កាត់ ត្រូវថតចម្លងលិខិតសំរេចប្រគល់កិច្ចសន្យាភ្ជាប់ជាមួយរបាយការណ៍បើកឯកសារដេញថ្លៃ និងកំណត់ហេតុវាយតំលៃសំណើដេញថ្លៃ ដើម្បីប្រគល់កិច្ចសន្យាជូនអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត-ក្រុង។
- អ្នកដេញថ្លៃណាយល់ឃើញថា ការសំរេចប្រគល់កិច្ចសន្យាខាងលើធ្វើមិនបានត្រឹមត្រូវនោះមានសិទ្ធិដាក់ពាក្យបណ្តឹងតវ៉ាទៅអភិបាលខេត្ត ក្រុង មិនអោយយឺតជាងពីរថ្ងៃធ្វើការបន្ទាប់ពីលទ្ធផលនៃការវាយតំលៃលើសំណើដេញថ្លៃត្រូវបានផ្សព្វផ្សាយជាសាធារណៈ។
  ការដាក់ពាក្យបណ្តឹងតវ៉ានេះ អ្នកដេញថ្លៃត្រូវផ្តល់នូវភស្តុតាងគ្រប់គ្រាន់សំរាប់គាំទ្រចំពោះការតវ៉ារបស់ខ្លួន និងថតចំលងពាក្យបណ្តឹងតវ៉ានេះមួយច្បាប់ផ្ញើជូនមេឃុំ ចៅសង្កាត់ ជ្រាបជាពត៌មាន ។
- អភិបាលខេត្ត ក្រុង ជាអ្នកធ្វើសេចក្តីសំរេចលើបណ្តឹងតវ៉ារបស់អ្នកដេញថ្លៃ ក្នុងរយៈពេលប្រាំថ្ងៃធ្វើការបន្ទាប់ពីបានទទួលពាក្យបណ្តឹងតវ៉ា ។ សេចក្តីសំរេចរបស់អភិបាលខេត្ត ក្រុង ចាត់ទុកជាការសំរេចចុងក្រោយ និងបិទការតវ៉ាពីគ្រប់ភាគី ។
- ក្រោយរយៈពេលប្រាំពីរថ្ងៃធ្វើការ ដែលអភិបាលខេត្ត-ក្រុងបានទទួលលិខិតជ្រើសរើសអ្នកទទួលការដើម្បីប្រគល់កិច្ចសន្យា និងមិនមានការជំទាស់ជាលាយលក្ខណ៍អក្សរនោះ មេឃុំ ចៅ សង្កាត់ ដោយមានជំនួយពីមន្ត្រីគាំទ្របច្ចេកទេសត្រូវរៀបចំចុះកិច្ចសន្យា និងប្រគល់ការងារអោយអ្នកដេញថ្លៃឈ្នះដើម្បីអនុវត្ត ។
- មេឃុំ ចៅសង្កាត់ ត្រូវភ្ជាប់លិខិតសំរេចជ្រើសរើសអ្នកទទួលការដើម្បីប្រគល់កិច្ចសន្យា និងកិច្ចសន្យាមួយច្បាប់ក្បាប់ជាមួយនឹងសំណើទូទាត់លើកដំបូង ផ្ញើជូនគណនេយ្យករឃុំ សង្កាត់នៅរតនាគារខេត្ត-ក្រុង។

២០ ក្នុងដំណើរការដេញថ្លៃ មេឃុំ ចៅសង្កាត់ត្រូវធ្វើយ៉ាងណាអោយអ្នកម៉ៅការ ឬអ្នកផ្គត់ផ្គង់ចូលរួមដេញថ្លៃបានច្រើនបំផុត តាមតែអាចធ្វើទៅបាន ។ មេឃុំ ចៅសង្កាត់ អាចសំរេចចិត្តអនុវត្តកិច្ចការមួយចំនួនដូចជា : 4

- ការណែនាំពីបច្ចេកទេស
- ការបញ្ជូនឯកសារដេញថ្លៃ
- ការបើកឯកសារដេញថ្លៃ
- រួមគ្នាធ្វើការវាយតំលៃលើការដេញថ្លៃនៅក្នុងរយៈពេលកន្លះថ្ងៃ ។

២១ ចំពោះការងាររដ្ឋបាល ស្តីពីការងារកិច្ចសន្យាទាំងអស់ នឹងតម្រូវអោយមានការត្រួតពិនិត្យផ្នែកបច្ចេកទេស ដែលត្រូវអនុវត្តដោយ "អ្នកត្រួតពិនិត្យបច្ចេកទេស" ដែលមានការទទួលខុសត្រូវដូចខាងក្រោម:

- ការត្រួតពិនិត្យនៅទីកន្លែងជាក់ស្តែង លើការអនុវត្តកិច្ចសន្យា និងធ្វើការណែនាំលើការងារពាក់ព័ន្ធដល់អ្នកទទួលការ
- ការបញ្ជាក់លើបរិមាណ និងគុណភាពនៃការងារ ដែលបានអនុវត្តដោយអ្នកទទួលការ
- ការផ្ទៀងផ្ទាត់សំណើទូទាត់តាមកិច្ចសន្យា។

## VI.2 លទ្ធកម្មការងារសេវា និងសេវាទីប្រឹក្សា

២២ ដោយទទួលបានការអនុញ្ញាតពីក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់អាចតែងតាំងអ្នកមានជំនាញអាជីពម្នាក់ពីផ្នែកឯកជន ឬអង្គភាពមិនគិតប្រាក់ចំណេញ អោយធ្វើជាអ្នកត្រួតពិនិត្យបច្ចេកទេស ។ អ្នកត្រួតពិនិត្យបច្ចេកទេស ដែលតែងតាំងដោយមេឃុំ ចៅសង្កាត់ ត្រូវមានវិញ្ញាបនប័ត្រចុះបញ្ជីនៅការិយាល័យខេត្ត ក្រុង ។

២៣ ការជ្រើសរើសអ្នកត្រួតពិនិត្យបច្ចេកទេសឯករាជ្យ ត្រូវតែធ្វើឡើងជាសាធារណៈ និងមានតម្លាភាព។ សំណើសំរាប់សេវាបច្ចេកទេសនានា ត្រូវបិទផ្សាយលើក្តារពត៌មានផ្លូវការនៅការិយាល័យរដ្ឋបាលខេត្ត ក្រុង និងឃុំ សង្កាត់ អោយបានពីរសប្តាហ៍មុនពេលធ្វើការជ្រើសរើស ។ រាល់ការស្នើសុំផ្តល់សេវាកម្មទាំងអស់ ត្រូវដាក់ជូនតាមទំរង់ស្តង់ដារ ដើម្បីជាលទ្ធភាពអាចអោយគេធ្វើការវាយតម្លៃ ប្រៀបធៀបលើលក្ខណៈសម្បត្តិជំនាញ បទពិសោធន៍ និងកំរៃទូទាត់ ។ រាល់ការស្នើសុំទាំងអស់ នឹងត្រូវពិនិត្យឡើងវិញដោយគណៈកម្មការលទ្ធកម្ម និងធ្វើអនុសាសន៍លើការជ្រើសរើសអ្នកត្រួតពិនិត្យបច្ចេកទេសអោយមេឃុំ ចៅសង្កាត់ ដើម្បីផ្តល់កិច្ចសន្យា ។

២៤ ដំណើរការតែងតាំងអ្នកត្រួតពិនិត្យបច្ចេកទេសឯករាជ្យ ត្រូវរៀបចំតាមលំនាំដូចគ្នានឹងការផ្តល់កិច្ចសន្យាការងារសាងសង់ដែរ ។

២៥ កំរៃសំរាប់ទូទាត់ដល់អ្នកត្រួតពិនិត្យបច្ចេកទេសឯករាជ្យ ត្រូវរៀបចំទុក និងគិតគូរដោយឃុំ សង្កាត់ ហើយត្រូវបានគិតបញ្ចូលទៅក្នុងតំលៃវិនិយោគសរុប នៃកិច្ចសន្យាដែលពាក់ព័ន្ធ ។

២៦ ការផ្តល់កិច្ចសន្យាសេវាកម្មវិជ្ជាជីវៈទាំងអស់ ដែលមានតម្រូវការនៅក្នុងការអនុវត្តវិនិយោគមូលដ្ឋាន ត្រូវធ្វើឡើងតាមលំនាំដូចគ្នាទៅនឹងការងារសំណង់វិស្វកម្មដែរ ។

## VI.3 លទ្ធកម្មសំភារៈ ឬទំនិញ

២៧ ការទិញសំភារៈ ឬទំនិញផ្សេងៗ ត្រូវអនុវត្តតាមនីតិវិធីដេញថ្លៃជាធារណៈ វិធីសាស្ត្រស្ទង់តំលៃក្នុងស្រុក និង វិធីសាស្ត្រទិញផ្ទាល់ តាមកំរិតទឹកប្រាក់ដែលបានកំណត់ក្នុង កថាខ័ណ្ឌ V.2។

**វិធីសាស្ត្រដេញថ្លៃជាសាធារណៈ**

វិធីសាស្ត្រនេះមានលក្ខណៈប្រហាក់ប្រហែល នឹងវិធីសាស្ត្រដេញថ្លៃជាសាធារណៈ នៃការងារសាងសង់ដែរ ។

**វិធីសាស្ត្រស្ទង់តំលៃក្នុងស្រុក**

វិធីសាស្ត្រនេះមាននីតិវិធីប្រហាក់ប្រហែល នឹងវិធីសាស្ត្រដេញថ្លៃជាសាធារណៈ គ្រាន់តែមិនមានលក្ខណៈប្រកួតប្រជែងជាចំហ (ជាសាធារណៈ)។ វិធីសាស្ត្រនេះមាននីតិវិធីដូចខាងក្រោម:

**ក. ការរៀបចំ និងការចេញលិខិតអញ្ជើញអំពីការស្ទង់តម្លៃ**

- មេឃុំ ចៅសង្កាត់ ឬអ្នកទទួលសិទ្ធិ ត្រូវរៀបចំឯកសារស្ទង់តំលៃអោយបានរួចរាល់ បន្ទាប់មកចេញលិខិតអញ្ជើញអ្នកផ្គត់ផ្គង់ យ៉ាងតិចបី អោយមកបំពេញ និងដាក់សំណើស្ទង់តំលៃក្នុងតារាងតំលៃ ដោយមានបញ្ជាក់អំពីលក្ខណៈបច្ចេកទេស និងលក្ខខណ្ឌនៃការប្រគល់ ទទួលទំនិញ ឬសំភារៈ។

**ខ. ការវាយតំលៃលើសំណើស្ទង់តំលៃក្នុងស្រុក**

- ប្រសិនបើការស្នើសុំទិញ មានចំនួនទឹកប្រាក់ស្មើ ឬលើសពី ២ ០០០ ០០០ រៀល គណៈកម្មការលទ្ធកម្ម ត្រូវវាយតម្លៃសំណើស្ទង់តំលៃដែលបានទទួល ។ ការវាយតំលៃលើសំណើស្ទង់តំលៃនេះត្រូវធ្វើឡើងតាមលំនាំដូចគ្នានឹងការវាយតំលៃលើការដេញថ្លៃជាសាធារណៈដែរ ។
- ប្រសិនបើការស្នើសុំទិញមានចំនួនទឹកប្រាក់តិចជាង ២ ០០០ ០០០ រៀល មេឃុំ ចៅសង្កាត់ឬអ្នកទទួលសិទ្ធិ ត្រូវទទួលខុសត្រូវលើការវាយតំលៃ ដោយមានជំនួយការពីមន្ត្រីគាំទ្របច្ចេកទេស។
- ចំពោះករណីទាំងពីរខាងលើនេះ ការវាយតំលៃត្រូវផ្តោតទៅលើអនុលោមភាពនៃសំភារៈ ឬទំនិញ ដែលបានស្នើឡើងតាមការស្ទង់តំលៃ និងលក្ខខណ្ឌនៃការប្រគល់ ទទួល ។ ការស្ទង់តំលៃដែលបានទទួល និងកំនត់ហេតុនៃការវាយតំលៃ ត្រូវភ្ជាប់ជាមួយនឹងសំណើទូទាត់ និងដាក់ជូនទៅគណនេយ្យករឃុំ សង្កាត់ នៅពេលដែលសំភារៈ ឬទំនិញ បានប្រគល់ ទទួល ។

**គ. ការចេញលិខិតបញ្ជាទិញ**

មេឃុំ ចៅសង្កាត់ និងអ្នកទទួលសិទ្ធិ ត្រូវចេញលិខិតបញ្ជាទិញទៅអ្នកផ្គត់ផ្គង់ តាមដំណើរការវាយតំលៃលើតំលៃស្នង ។

២៨ ករណីលើកលែង ចំពោះការធ្វើលទ្ធកម្មតាមវិធីសាស្ត្រស្ទង់តំលៃ ដូចដែលបានបញ្ជាក់ក្នុង ចំណុច ២៧ នឹងត្រូវធ្វើឡើងសំរាប់ការទិញម្តងម្កាល និងការទិញសំភារៈ ឬទំនិញ ដែលមានតំលៃទឹកប្រាក់ សរុបតិចជាង ៤០០.០០០ រៀល ។ ក្នុងករណីបែបនេះមេឃុំ ចៅសង្កាត់ ឬអ្នកទទួលសិទ្ធិ ត្រូវអនុវត្តតាមនីតិវិធីទិញផ្ទាល់ ឬការចុះកិច្ចសន្យាផ្ទាល់ ដូចដែលបានបញ្ជាក់ ខាងក្រោម :

**ក. ការរៀបចំ និងការចេញលិខិតអញ្ជើញ**

មេឃុំ ចៅសង្កាត់ ឬអ្នកទទួលសិទ្ធិ ត្រូវរៀបចំការស្រង់តំលៃដោយចេញលិខិតអញ្ជើញអ្នកផ្គត់ផ្គង់ណាមួយ អោយដាក់សំរង់តំលៃដោយបញ្ជាក់អំពីលក្ខណៈ និងលក្ខខណ្ឌនៃការប្រគល់ ទទួលសំភារៈ ឬទំនិញ ដោយមានជំនួយការពីមន្ត្រីគាំទ្របច្ចេកទេស ។

**ខ. ការវាយតំលៃលើសម្រង់តំលៃ និងការចរចាថ្លៃ**

- ប្រសិនបើការស្នើថ្លៃ បានឆ្លើយតបនឹងសេចក្តីបញ្ជាក់លើលក្ខណៈ និងលក្ខខណ្ឌនៃការអញ្ជើញ អោយដាក់សម្រង់តំលៃ មេឃុំ ចៅសង្កាត់ ត្រូវចរចាថ្លៃជាមួយអ្នកផ្គត់ផ្គង់ ដើម្បីសំរបសំរួលជាមួយនឹងតំលៃប៉ាន់ស្មានរបស់រដ្ឋបាលឃុំ សង្កាត់ ។
- ប្រសិនបើការចរចារថ្លៃ មិនទទួលបានជោគជ័យ ដំណើរការដែលមានលំនាំដូចគ្នានេះត្រូវធ្វើឡើងវិញម្តងទៀត ជាមួយនឹងអ្នកផ្គត់ផ្គង់ម្នាក់ផ្សេងទៀត ។

**គ. ការចេញលិខិតបញ្ជាទិញ**

មេឃុំ ចៅសង្កាត់ ឬអ្នកទទួលសិទ្ធិ ត្រូវចេញលិខិតបញ្ជាទិញ បន្ទាប់ពីការចរចាថ្លៃបានឈានដល់ការព្រមព្រៀងគ្នាហើយ ។

២៩ មេឃុំ ចៅសង្កាត់ អាចស្នើសុំការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីអភិបាលខេត្ត ក្រុង ដើម្បីលើកលែងការធ្វើលទ្ធកម្មតាមលក្ខណៈប្រកួតប្រជែងជាចំហ និងប្រើជាជំនួសវិញដោយការទិញផ្ទាល់ ឬការចុះកិច្ចសន្យា ដែលបានបញ្ជាក់ក្នុងចំណុច ២៨ ខាងលើ ចំពោះករណីដូចខាងក្រោម ដោយមិនគិតពីចំនួនទឹកប្រាក់នៃប្រតិបត្តិការឡើយ :

- ការធ្វើលទ្ធកម្មសំភារៈ ឬទំនិញ សេវាកម្ម និងការងារសាងសង់ ដែលមិនអាចរកបានអ្នកផ្គត់ផ្គង់ ឬអ្នកម៉ៅការសមរម្យ បន្ទាប់ពីបញ្ចប់ដំណើរការប្រកួតប្រជែងរួច
- ការធ្វើលទ្ធកម្មសំភារៈ ឬទំនិញ សេវាកម្ម និងការងារសាងសង់ ដែលមានលក្ខណៈបច្ចេកទេសអាចអនុវត្តបាន ចំពោះតែអ្នកផ្គត់ផ្គង់ ឬចំពោះតែអ្នកម៉ៅការតែម្នាក់
- ការធ្វើលទ្ធកម្មសំភារៈ ឬទំនិញ សេវាកម្ម និងការងារសាងសង់ ដែលមិនអាចជាកម្មវត្ថុនៃការពន្យាពេលដោយដំណើរការប្រកួតប្រជែងថ្លៃ ពីព្រោះវាមានលក្ខណៈជាបន្ទាន់ ដែលតម្រូវតាមកាលៈទេសៈ ហើយយើងមិនបានគ្រោងទុកជាមុន ។

មេឃុំ ចៅសង្កាត់ ត្រូវបញ្ជាក់អោយបានល្អិតល្អន់ នៅក្នុងសំណើសុំលើកលែងការធ្វើលទ្ធកម្ម តាមលក្ខណៈប្រកួតប្រជែងជាចំហ អំពីហេតុផលទាំងឡាយដូចបានបញ្ជាក់ក្នុងកថាខ័ណ្ឌនេះ ដើម្បីបង្ហាញពីភាពសមហេតុសមផល ក្នុងការអនុវត្តវិធីសាស្ត្រការទិញផ្ទាល់ ឬការចុះកិច្ចសន្យាផ្ទាល់ ។

ប្រកាសនេះជំនួសអោយប្រកាស លេខ ៩៣៧ សហវ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០២ ស្តីពី ការងារលទ្ធកម្មរបស់ឃុំ សង្កាត់។

ប្រកាសណែនាំខាងលើនេះ មានលក្ខណៈសង្ខេបអំពីគោលការណ៍សំខាន់ៗស្តីពីវិធីសាស្ត្រនិងនីតិវិធីលទ្ធកម្ម ក្នុងដំណើរការអនុវត្តចំណាយថវិការបស់ឃុំ សង្កាត់នីមួយៗ ក្នុងទូទាំងប្រទេស ។ ដូច្នេះក្នុងដំណើរការអនុវត្ត បើមានបញ្ហាអ្វីមិនទាន់ច្បាស់លាស់ សូមទាក់ទងជាបន្ទាន់មកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីពិភាក្សាដោះស្រាយអោយបានទាន់ពេលវេលា ។

រាជធានីភ្នំពេញ,ថ្ងៃទី ២៨ ខែមិនា ឆ្នាំ ២០០៣

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

**កន្លែងទទួល:**

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់
- ក្រសួងមហាផ្ទៃ
- គ្រប់សាលាខេត្ត ក្រុង
- គ្រប់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្ត ក្រុង
- គ្រប់រតនាគារខេត្ត ក្រុង
- គ្រប់ឃុំ សង្កាត់
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១៧៣ សហវ

## ប្រកាសអន្តរក្រសួង
## ស្តីពី
## ការកែប្រែសមាសភាពគណៈកម្មការគ្រប់គ្រងហិរញ្ញវត្ថុវិស័យអប់រំ

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**
**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

-បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែតុលា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញ ព្រះរាជក្រមនស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើ ច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញ អនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រសួងសេដ្ឋិច្ច និងហិរញ្ញវត្ថុ

-បានឃើញ ប្រកាសលេខ ៧៦០ សហវ វស ចុះថ្ងៃទី ១១ ខែតុលា ឆ្នាំ ២២០១ ស្តីពីការបង្កើតគណៈគ្រប់គ្រងហិរញ្ញវត្ថុសំរាប់វិស័យអប់រំ

-បានឃើញ អនុស្សារណៈ រវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា

-យោងតាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា

**សំរេច**

**ប្រការ១:** ផ្លាស់ប្តូរសមាសភាពគណៈកម្មការគ្រប់គ្រងហិរញ្ញវត្ថុ និងសមាសភាពក្រុមការងារបច្ចេកទេសហិរញ្ញវត្ថុ សំរាប់វិស័យអប់រំ ដែលមានសមាសភាពថ្មីដូចខាងក្រោម:

**ប្រការ២.-** ផ្ទេរភារកិច្ច លោក ហួត វ៉ាន់ហាន បច្ចុប្បន្នអនុប្រធានការិយាល័យចំណាយថវិកាជាតិ មកជាអនុប្រធានរតនាគារខេត្តកំពង់ឆ្នាំង ។

**ប្រការ៣.-** អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធានរតនាគារជាតិ និង អង្គភាពពាក់ព័ន្ធ ព្រមទាំងសាមីខ្លួនដូចក្នុងប្រការ១និង២ខាងលើ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ២០០៣

**គាត ឈន់**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- សាលាខេត្តកំពង់ស្ពឺ-ខេត្តកំពង់ឆ្នាំង

"ដើម្បីជូនជ្រាប"

- ដូចប្រការ៣
- កាលប្បវត្តិ-ឯកសារ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និង កីឡា**

លេខ ៤៨៥ អយក.ប្រក

# ប្រ កា ស

## ស្តីពីការបើកអនុវិទ្យាល័យ កោះជីវាំង ស្ថិតនៅក្នុងឃុំកោះជីវាំង ស្រុកឯកភ្នំ ខេត្តបាត់ដំបង

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា**

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១១៩៨_៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស_៩៤ ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស_រកម ០១៩៦_០១ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស_រកត ០៧៩៦_៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ_បក ចុះថ្ងៃទី ២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទមចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១_កំរិត២
- យោងលិខិតស្នើសុំរបស់សហគមន៍ឃុំកោះជីវាំង ស្រុកឯកភ្នំ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០០២ ដោយមានយោបល់ឯកភាព ពីមន្ទីរអប់រំ យុវជន និងកីឡា និងអភិបាលខេត្តបាត់ដំបង
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ

**សំ រេ ច**

**ប្រការ ១ :** អនុញ្ញាតអោយបើកអនុវិទ្យាល័យដែលមានឈ្មោះថា : អនុវិទ្យាល័យ « កោះជីវាំង » ស្ថិតនៅក្នុងឃុំកោះជីវាំង ស្រុកឯកភ្នំ ខេត្តបាត់ដំបង ចាប់ពីឆ្នាំសិក្សា ២០០២_២០០៣ តទៅ ។

**ប្រការ ២ :** អនុវិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗ មួយចំនួនទៀតតាមអង្គការលេខ នៃអនុវិទ្យាល័យ ។

**ប្រការ ៣ :** នាយក_នាយករងនៃអនុវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

**ប្រការ ៤ :** អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡាខេត្តបាត់ដំបង និងនាយកអនុវិទ្យាល័យសាមីមាន ភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
  " ដើម្បីជ្រាបជាពត៌មាន "
- សាលាខេត្តបាត់ដំបង " ដើម្បីជាពត៌មាន "
- ដូចប្រការ ៤
- កាលប្បវត្តិ_ឯកសារ នា.មចទ

ភ្នំពេញ , ថ្ងៃទី២៤ ខែមករា ឆ្នាំ ២០០៣

ជ. រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

រដ្ឋលេខាធិការ

អ៊ឹម សិទ្ធី

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និង កីឡា**

លេខ ៧៥៩ អយក.ប្រក

# ប្រកាស

ស្តីពីការពង្រីក និងប្តូរឈ្មោះអនុវិទ្យាល័យ

« បទុមសុរិយា » ទៅជាវិទ្យាល័យ « សុខ អាន សំរោង »

ស្ថិតនៅក្នុងឃុំខ្វាវ ស្រុកសំរោង ខេត្តតាកែវ

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១១៩៨_៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស_៩៤ ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស_រកម ០១៩៦_០១ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស_រកត ០៧៩៦_៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ_បក ចុះថ្ងៃទី ២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទមចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១_កំរិត២
- យោងលិខិតស្នើសុំរបស់សហគមន៍ឃុំខ្វាវ ស្រុកសំរោង ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៣ ដោយមានយោបល់ឯកភាពពី មន្ទីរអប់រំ យុវជន និងកីឡា និង អភិបាលខេត្តតាកែវ
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ

## សំរេច

**ប្រការ ១ :** អនុញ្ញាតអោយពង្រីក និងប្តូរឈ្មោះអនុវិទ្យាល័យ « បទុមសុរិយា » បច្ចុប្បន្ន ទៅជាវិទ្យាល័យ « សុខ អាន សំរោង » ស្ថិតនៅក្នុងឃុំខ្វាវ ស្រុកសំរោង ខេត្តតាកែវ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ប្រការ ២ :** វិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និង នាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗមួយចំនួនទៀតតាមអង្គការលេខនៃវិទ្យាល័យ ។

**ប្រការ ៣ :** នាយក_នាយករងនៃវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

**ប្រការ ៤ :** បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៥ :** អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុក្រសួងអប់រំយុវជននិងកីឡា មន្ទីរអប់រំ យុវជន និងកីឡាខេត្តតាកែវ និងនាយកវិទ្យាល័យសាមីមានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ភ្នំពេញ , ថ្ងៃទី ២៥ ខែ ៣ ឆ្នាំ ២០០៣

ក្រសួងអប់រំ យុវជន និងកីឡា

រដ្ឋមន្ត្រី

**ទ្បឹម_សិទ្ធិ**

**កន្លែងទទួល**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ "ដើម្បីជ្រាបជាពត៌មាន"
- សាលាខេត្តតាកែវ "ដើម្បីជាពត៌មាន"
- ដូចប្រការ ៥
- កាលប្បវត្តិ_ឯកសារ នា.មចទ

C:\New school\Increase 2.doc

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

លេខ : ៣០១ អយក.ប្រក

# ប្រកាស

## ស្តីពី ការផ្តាច់សាលាឧបសម្ព័ន្ធ ល្វឹម មកជាសាលាបឋមសិក្សាពេញលក្ខណៈ

---

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញព្រះរាជក្រឹត្យ លេខ នស.រកត -១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.ប.ក ចុះថ្ងៃទី ២៣ ខែ មិនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញអនុក្រឹត្យលេខ ១០៤ អនក្រ-បក ចុះថ្ងៃទី១៤ ខែ តុលា ឆ្នាំ ២០០២ ស្តីពីការកែសំរួលរចនាសម្ព័ន្ធនាយកដ្ឋានបឋមនិងមត្តេយ្យសិក្សា ជា នាយកដ្ឋានបឋមសិក្សា និង នាយកដ្ឋានអប់រំកុមារតូច

-បានពិនិត្យលិខិត លេខ ៦៨៨ អយក ចុះថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ២០០២ របស់មន្ទីរអប់រំយុវជន និង កីឡា ខេត្ត **កំពង់ស្ពឺ**

-តាមយោបល់ឯកភាពរបស់ **នាយកដ្ឋានបឋមសិក្សា**

## សំរេច

**ប្រការ១:** ផ្តាច់សាលាឧបសម្ព័ន្ធ **ល្វឹម** ពីសាលាបឋមសិក្សា **បន្ទាយប្រណាក** ដែលមានទីតាំងស្ថិតនៅ ភូមិ **ល្វឹម** ឃុំ **ត្រពាំងជោរ** ស្រុក **ឱរ៉ាល់** ខេត្ត **កំពង់ស្ពឺ** មកជាសាលាបឋមសិក្សាពេញលក្ខណៈវិញ ចាប់ពីឆ្នាំសិក្សា ២០០២-២០០៣ នេះតទៅ ។

**ប្រការ២:** សាលាបឋមសិក្សា **ល្វឹម** ត្រូវដឹកនាំដោយ នាយកមួយរូប និង នាយករង តាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗ ស្របតាមបទដ្ឋានប្រើប្រាស់ក្របខ័ណ្ឌ សំរាប់សាលាបឋមសិក្សា ។

**ប្រការ៣:** នាយក នាយករង មានសិទ្ធិទទួលប្រាក់បំនាច់ភារកិច្ច តាមគោលការណ៍កំនត់របស់រដ្ឋ ។

**ប្រការ៤:** បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៥:** អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានបឋមសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត **កំពង់ស្ពឺ** ការិយាល័យអប់រំ យុវជន និងកីឡាស្រុក **ឱរ៉ាល់** នាយកសាលាបឋមសិក្សា **ល្វឹម** នាយកសាលាបឋមសិក្សា **បន្ទាយប្រណាក** មានភារកិច្ចអនុវត្តប្រកាសនេះ ។

**កន្លែងទទួល**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

-ក្រសួងផែនការ-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-សាលាខេត្ត កំពង់ស្ពឺ

**"ដើម្បីជូនជ្រាបជាពត៌មាន"**

-ដូចប្រការ ៥

-កាលប្បវត្តិ-ឯកសារ ទា .បស

ភ្នំពេញ , ថ្ងៃទី២៦ ខែ មិនា ឆ្នាំ ២០០៣

ជ. រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

រដ្ឋលេខាធិការ

អ៊ឹុម-សិទ្ធី

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

លេខ : ៧០៣ អយក.ប្រក

# ប្រកាស

## ស្តីពី ការផ្តាច់សាលាឧបសម្ព័ន្ធ តាំងចំពង់ មកជាសាលាបឋមសិក្សាពេញលក្ខណៈ

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា**

-បានឃើញព្រះរាជក្រឹត្យ លេខ នស.រកត -១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.ប.ក ចុះថ្ងៃទី ២៣ ខែ មិនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញអនុក្រឹត្យលេខ ១០៤ អនក្រ-បក ចុះថ្ងៃទី១៤ ខែ តុលា ឆ្នាំ ២០០២ ស្តីពីការកែសំរួលរចនាសម្ព័ន្ធនាយកដ្ឋានបឋមនិងមត្តេយ្យសិក្សា ជានាយកដ្ឋានបឋមសិក្សា និង នាយកដ្ឋានអប់រំកុមារតូច

-បានពិនិត្យលិខិតលេខ ៦៩៣ អយក ចុះថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ២០០២ របស់ មន្ទីរ អប់រំយុវជន និង កីឡា ខេត្ត **កំពង់ស្ពឺ**

-តាមយោបល់ឯកភាពរបស់ **នាយកដ្ឋានបឋមសិក្សា**

## សំ រេ ច

**ប្រការ១:** ផ្តាច់សាលាឧបសម្ព័ន្ធ **តាំងចំពង់** ពីសាលាបឋមសិក្សា **រលាក់កងជើង** ដែលមានទីតាំងស្ថិតនៅ ភូមិ **តាំងចំពង់** ឃុំ **តាសាល** ស្រុក **ឱរ៉ាល់** ខេត្ត **កំពង់ស្ពឺ** មកជាសាលាបឋមសិក្សាពេញលក្ខណៈវិញ ចាប់ពីឆ្នាំសិក្សា ២០០២-២០០៣ នេះតទៅ ។

**ប្រការ២:** សាលាបឋមសិក្សា **តាំងចំពង់** ត្រូវដឹកនាំដោយ នាយកមួយរូប និង នាយករង តាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗ ស្របតាមបទដ្ឋានប្រើប្រាស់ក្របខ័ណ្ឌសំរាប់សាលាបឋមសិក្សា ។

**ប្រការ៣:** នាយក នាយករង មានសិទ្ធិទទួលប្រាក់បំនាច់ភារកិច្ច តាមគោលការណ៍កំនត់របស់រដ្ឋ ។

**ប្រការ៤:** បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៥:** អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានបឋមសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត **កំពង់ស្ពឺ** ការិយាល័យអប់រំ យុវជន និងកីឡាស្រុក **ឱរ៉ាល់**នាយកសាលាបឋមសិក្សា **តាំងចំពង់**នាយកសាលាបឋមសិក្សា **រលាក់កងជើង** មានភារកិច្ចអនុវត្តប្រកាសនេះ ។

ភ្នំពេញ , ថ្ងៃទី២៦ ខែមីនា ឆ្នាំ ២០០៣

ជ. **រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**រដ្ឋលេខាធិការ**

**អ៊ឹម សិទ្ធី**

**កន្លែងទទួល**

- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- -ក្រសួងផែនការ-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- -សាលាខេត្ត កំពង់ស្ពឺ

**"ដើម្បីជូនជ្រាបជាពត៌មាន"**

- -ដូចប្រការ ៥
- -កាលប្បវត្តិ-ឯកសារ នា .បស

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

៣ ❖ ៤

ក្រសួងអប់រំ យុវជន និងកីឡា

លេខ : ៧០៤ អយក.ប្រក

## ប្រកាស

ស្តីពី ការផ្តាច់សាលាឧបសម្ព័ន្ធ ត្រពាំងកោង

មកជាសាលាបឋមសិក្សាពេញលក្ខណ:

---

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា**

-បានឃើញព្រះរាជក្រឹត្យ លេខ នស.រកត -១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណ:រដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.ប.ក ចុះថ្ងៃទី ២៣ ខែ មិនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញអនុក្រឹត្យលេខ ១០៤ អនក្រ-បក ចុះថ្ងៃទី១៤ ខែ តុលា ឆ្នាំ ២០០២ ស្តីពីការកែសំរួលរចនាសម្ព័ន្ធនាយកដ្ឋានបឋមនិងមត្តេយ្យសិក្សា ជានាយកដ្ឋានបឋមសិក្សា និង នាយកដ្ឋានអប់រំកុមារតូច

-បានពិនិត្យលិខិតលេខ ៦៩០ អយក ចុះថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ២០០២ របស់ មន្ទិរ អប់រំយុវជន និង កីឡា ខេត្ត **កំពង់ស្ពឺ**

-តាមយោបល់ឯកភាពរបស់ **នាយកដ្ឋានបឋមសិក្សា**

**ស ំ រេ ច**

**ប្រការ១:** ផ្តាច់សាលាឧបសម្ព័ន្ធ **ត្រពាំងកោង** ពីសាលាបឋមសិក្សា **សម្តេចជាស៊ីម** ដែលមានទីតាំងស្ថិតនៅ ភូមិ **ត្រពាំងកោង** ឃុំ **សង្កែសាធប** ស្រុក **ឱរ៉ាល់** ខេត្ត **កំពង់ស្ពឺ** មកជាសាលាបឋមសិក្សាពេញលក្ខណ:វិញ ចាប់ពីឆ្នាំសិក្សា ២០០២-២០០៣ នេះតទៅ ។

**ប្រការ២:** សាលាបឋមសិក្សា **ត្រពាំងកោង** ត្រូវដឹកនាំដោយ នាយកមួយរូប និង នាយករង តាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗស្របតាមបទដ្ឋានប្រើប្រាស់ក្របខ័ណ្ឌសំរាប់សាលាបឋមសិក្សា ។

**ប្រការ៣:** នាយក នាយករង មានសិទ្ធិទទួលប្រាក់បំនាច់ភារកិច្ច តាមគោលការណ៍កំនត់របស់រដ្ឋ ។

**ប្រការ៤:** បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៥:** អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានបឋមសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត **កំពង់ស្ពឺ** ការិយាល័យអប់រំ យុវជន និងកីឡាស្រុក **ឱរ៉ាល់** នាយកសាលាបឋមសិក្សា **ត្រពាំងកោង** នាយកសាលាបឋមសិក្សា **សម្តេច ជាស៊ីម** មានភារកិច្ចអនុវត្តប្រកាសនេះ ។

ភ្នំពេញ , ថ្ងៃទី២៦ ខែមិនា ឆ្នាំ ២០០៣

ឧ. **រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**រដ្ឋលេខាធិការ**

**អ៊ឹម_សិទ្ធី**

**កន្លែងទទួល**

-ទីស្តីការគណ:រដ្ឋមន្ត្រី

-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណ:

-ក្រសួងផែនការ-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-សាលាខេត្ត កំពង់ស្ពឺ

**"ដើម្បីជូនជ្រាបជាព័ត៌មាន"**

-ដូចប្រការ ៥

-កាលប្បវត្តិ-ឯកសារ ឆា បស

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

៚ ❖ ៛

ក្រសួងអប់រំ យុវជន និងកីឡា

លេខ : ៣០៥ អយក.ប្រក

# ប្រកាស

ស្តីពី ការផ្តាច់សាលាឧបសម្ព័ន្ធ សំរោង

មកជាសាលាបឋមសិក្សាពេញលក្ខណៈ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញព្រះរាជក្រឹត្យ លេខ នស.រកត -១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ.កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.ប.ក ចុះថ្ងៃទី ២៣ ខែ មិនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញអនុក្រឹត្យលេខ ១០៤ អនក្រ-បក ចុះថ្ងៃទី១៤ ខែ តុលា ឆ្នាំ ២០០២ ស្តីពីការកែសំរួលរចនាសម្ព័ន្ធនាយកដ្ឋានបឋមនិងមត្តេយ្យសិក្សា ជា នាយកដ្ឋានបឋមសិក្សា និង នាយកដ្ឋានអប់រំកុមារតូច

-បានពិនិត្យលិខិតលេខ ៦៩២ អយក ចុះថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ២០០២ របស់ មន្ទីរ អប់រំយុវជន និង កីឡា ខេត្ត **កំពង់ស្ពឺ**

-តាមយោបល់ឯកភាពរបស់ **នាយកដ្ឋានបឋមសិក្សា**

## សំ រេ ច

**ប្រការ១:** ផ្តាច់សាលាឧបសម្ព័ន្ធ **សំរោង** ពីសាលាបឋមសិក្សា **ឆ្អិន** ដែលមានទីតាំងស្ថិតនៅ ភូមិ **សំរោង** ឃុំ **ត្រពាំងជោរ** ស្រុក **ឱរ៉ាល់** ខេត្ត **កំពង់ស្ពឺ** មកជាសាលាបឋមសិក្សាពេញលក្ខណៈវិញ ចាប់ពីឆ្នាំសិក្សា ២០០២-២០០៣ នេះតទៅ ។

**ប្រការ២:** សាលាបឋមសិក្សា **សំរោង** ត្រូវដឹកនាំដោយ នាយកមួយរូប និង នាយករង តាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងស្របតាមបទដ្ឋានប្រើប្រាស់ក្របខ័ណ្ឌ សំរាប់សាលាបឋមសិក្សា ។

**ប្រការ៣:** នាយក នាយករង មានសិទ្ធិទទួលប្រាក់បំនាច់ភារកិច្ច តាមគោលការណ៍កំនត់របស់រដ្ឋ ។

**ប្រការ៤:** បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៥:** អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានបឋមសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត **កំពង់ស្ពឺ** ការិយាល័យអប់រំ យុវជន និងកីឡាស្រុក **ឱរ៉ាល់** នាយកសាលាបឋមសិក្សា **សំរោង** នាយកសាលាបឋមសិក្សា **ឆ្អិន** មានភារកិច្ចអនុវត្តប្រកាសនេះ ៗ

ភ្នំពេញ, ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០៣

ស.រ.ដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

រដ្ឋលេខាធិការ

អ៊ឹម សិទ្ធី

**កន្លែងទទួល**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

-ក្រសួងផែនការ-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-សាលាខេត្ត កំពង់ស្ពឺ

**"ដើម្បីជូនជ្រាបជាពត៌មាន"**

-ដូចប្រការ ៥

-កាលប្បវត្តិ-ឯកសារ នា.បស

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

លេខ : ៣០៦ អយក.ប្រក

# ប្រកាស

## ស្តីពី ការផ្តាច់សាលាឧបសម្ព័ន្ធ **ត្រពាំងត្បែង** មកជាសាលាបឋមសិក្សាពេញលក្ខណៈ

---

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញព្រះរាជក្រឹត្យ លេខ នស.រកត -១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.ប.ក ចុះថ្ងៃទី ២៣ ខែ មិនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញអនុក្រឹត្យលេខ ១០៤ អនក្រ-បក ចុះថ្ងៃទី១៤ ខែ តុលា ឆ្នាំ ២០០២ ស្តីពីការកែសំរួលរចនាសម្ព័ន្ធនាយកដ្ឋានបឋមនិងមត្តេយ្យសិក្សា ជា នាយកដ្ឋានបឋមសិក្សា និង នាយកដ្ឋានអប់រំកុមារតូច

-បានពិនិត្យលិខិតលេខ ៦៨៩ អយក ចុះថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ២០០២ របស់ មន្ទីរ អប់រំយុវជន និង កីឡា ខេត្ត **កំពង់ស្ពឺ**

-តាមយោបល់ឯកភាពរបស់ **នាយកដ្ឋានបឋមសិក្សា**

## សំរេច

**ប្រការ១:** ផ្តាច់សាលាឧបសម្ព័ន្ធ **ត្រពាំងត្បែង** ពីសាលាបឋមសិក្សា **បន្ទាយប្រសាទ** ដែលមានទីតាំងស្ថិតនៅ ភូមិ **ត្រពាំងត្បែង** ឃុំ **ត្រពាំងជោរ** ស្រុក **ឱរ៉ាល់** ខេត្ត **កំពង់ស្ពឺ** មកជាសាលាបឋមសិក្សាពេញលក្ខណៈវិញ ចាប់ពីឆ្នាំសិក្សា ២០០២-២០០៣ នេះតទៅ ។

**ប្រការ២:** សាលាបឋមសិក្សា **ត្រពាំងត្បែង** ត្រូវដឹកនាំដោយ នាយកមួយរូប និង នាយករង តាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗ ស្របតាមបទដ្ឋានប្រើប្រាស់ក្របខ័ណ្ឌសំរាប់សាលាបឋមសិក្សា ។

**ប្រការ៣:** នាយក នាយករង មានសិទ្ធិទទួលប្រាក់បំនាច់ភារកិច្ច តាមគោលការណ៍កំនត់របស់រដ្ឋ ។

**ប្រការ៤:** បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៥:** អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានបឋមសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត **កំពង់ស្ពឺ** ការិយាល័យអប់រំ យុវជន និងកីឡាស្រុក **ឱរ៉ាល់** នាយកសាលាបឋមសិក្សា **ត្រពាំងត្បែង** នាយកសាលាបឋមសិក្សា **បន្ទាយប្រសាទ** មានភារកិច្ចអនុវត្តប្រកាសនេះ ។

ភ្នំពេញ, ថ្ងៃទី២៦ ខែ មីនា ឆ្នាំ ២០០៣

ជ. រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

រដ្ឋលេខាធិការ

អ៊ឹុង ស៊ិទ្ធី

**កន្លែងទទួល**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

-ក្រសួងផែនការ-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-សាលាខេត្ត **កំពង់ស្ពឺ**

**ដើម្បីជូនជ្រាបជាពត៌មាន**

-ដូចប្រការ ៥

-កាលប្បវត្តិ-ឯកសារ ទា.បស

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងអប់រំ យុវជន និងកីឡា

លេខ : ៣៦០ អយក.ប្រក

# ប្រកាស

ស្តីពី ការប្តូរឈ្មោះសាលាបឋមសិក្សា **ទួលសំបូរ**

មកជាសាលាបឋមសិក្សា **សុខ អាន ទួលសំបូរ**

---

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញព្រះរាជក្រឹត្យលេខនស-រកត ១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញអនុក្រឹត្យលេខ២១អនក្រ.ប.កចុះថ្ងៃទី២៣ ខែមិនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងអប់រំយុវជន និងកីឡា

-បានឃើញអនុក្រឹត្យលេខ ១០៤ អនក្រ-បក ចុះថ្ងៃទី១៤ ខែ តុលា ឆ្នាំ ២០០២ ស្តីពីការកែសំរួលរចនាសម្ព័ន្ធនាយកដ្ឋានបឋមនិងមត្តេយ្យសិក្សា ជានាយកដ្ឋានបឋមសិក្សា និង នាយកដ្ឋានអប់រំកុមារតូច

-បានពិនិត្យលិខិតរបស់ចៅអធិការគណៈកម្មការវត្ត នាយកសាលា លោកគ្រូ-អ្នកគ្រូ និងសមាគមមាតាបិតាសិស្ស ចំនុះជើង**វត្តទួលសំបូរ** ឃុំ **អង្គរបុរី** ស្រុក **អង្គរបុរី** ខេត្ត **តាកែវ** ចុះថ្ងៃទី ១៨ ខែ មិនា ឆ្នាំ ២០០៣ ដោយមានចំណារឯកភាព របស់មន្ទីរអប់រំយុវជន និងកីឡាខេត្ត **តាកែវ**

-តាមយោបល់ឯកភាពរបស់ **នាយកដ្ឋានបឋមសិក្សា**

## ស ំ រេ ច

**ប្រការ១** : ប្តូរឈ្មោះសាលាបឋមសិក្សា **ទួលសំបូរ** ដែលមានទីតាំងស្ថិតនៅ **វត្តទួលសំបូរ** ឃុំ **អង្គរបុរី** ស្រុក **អង្គរបុរី** ខេត្ត **តាកែវ** មកជា សាលាបឋមសិក្សា **សុខ អាន ទួលសំបូរ** វិញ ចាប់ពីឆ្នាំសិក្សា ២០០២-២០០៣ នេះតទៅ ។

**ប្រការ២** : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៣** : អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានបឋមសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត **តាកែវ** ការិយាល័យអប់រំ យុវជន និងកីឡាស្រុក **អង្គរបុរី** នាយកសាលាបឋមសិក្សា **សុខ អាន ទួលសំបូរ** មានភារកិច្ចអនុវត្តប្រកាសនេះ ។

ភ្នំពេញ , ថ្ងៃទី២៧ខែ មីនា ឆ្នាំ ២០០៣

**ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា**

**រដ្ឋលេខាធិការ**

**អ៊ឹម_សិទ្ធី**

**កន្លែងទទួល**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

-ក្រសួងផែនការ-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-សាលាខេត្ត **តាកែវ**

**" ដើម្បីជូនជ្រាបជាពត៌មាន"**

-ដូចប្រការ ៣

-កាលប្បវត្តិ-ឯកសារ នា.បស